ក្រសួងអប់រំជាតិ

# ស្ថានភាពខេមរយានកម្ម
# នៅមធ្យមសិក្សា
# ឆ្នាំ១៩៧២

វិទ្យាស្ថានជាតិខេមរយានកម្ម

ក្រសួងអប់រំជាតិ

# ស្ថានភាពខេមរយានកម្ម នៅមធ្យមសិក្សា ឆ្នាំ ១៩៧២,

វិទ្យាស្ថានជាតិខេមរយានកម្ម

# បញ្ជីអត្ថបទ

សេចក្តីផ្តើម ១

១ – ប្រវត្តិកំណើតអង្គការខេមរយានកម្ម ៤

២ – ទំរង់អង្គការខេមរយានកម្ម ៩

២-១- មុខងារនៃអង្គការខេមរយានកម្ម

២-២- គណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្ម

២-៣- អគ្គលេខាធិការដ្ឋាន

២-៤ គណៈកម្មាធិការពិសេស

២-៥- គណៈកម្មការបច្ចេកទេស

៣ – បុព្វហេតុនៃកំណើតខេមរយានកម្ម ១២

៤ – ប្រយោជន៍នៃអនុវត្តន៍ខេមរយានកម្ម ១៦

៤-១- ក្នុងវិស័យចិត្តគរុកោសល្យ

៤ ២ ក្នុងវិស័យអប់រំ

៤ ៣- ក្នុងវិស័យវប្បធម៌

៤-៤- ក្នុងវិស័យសេដ្ឋកិច្ច

៤-៥- ក្នុងវិស័យសង្គមកិច្ច

៤-៦- ក្នុងវិស័យនយោបាយ

៥– មធ្យោបាយនៃអនុវត្តន៍ខេមរយានកម្ម ១៨
៥ ១ បុគ្គលិក
៥-២- អ្នកនិពន្ធ
៥ ៣- ប្រាក់
៥ ៤ សម្ភារះនិងអគារ
៦– ដំណើរនៃអនុវត្តន៍ខេមរយានកម្មនៅមធ្យមសិក្សា ២១
៦ ១ ដំណាក់នៃអនុវត្តន៍
៦-២ តារាងកំរិតម៉ោងប្រចាំសប្តាហ៍ ( មធ្យមសិក្សា )
៧– ពាក្យគន្លឹះខេមរយានកម្ម ២៤
៧ ១- អ្វីទៅពាក្យគន្លឹះ ?
៧ ២- តើអនុម័តពាក្យគន្លឹះផ្អែកទៅលើគោលការណ៍អ្វីខ្លះ ?
៧-៣- តើពាក្យគន្លឹះត្រូវអនុម័តឲ្យប្រើតាមរបៀបណា ?
៧-៤- ចំនួនពាក្យគន្លឹះ
៨– សៀវភៅខេមរយានកម្ម ៣១
៨-១- តើអង្គការខេមរយានកម្មផលិតបានសៀវភៅអ្វីខ្លះ ?
៨ ២ តើអង្គការខេមរយានកម្មគ្រោងនឹងផលិត
សៀវភៅអ្វីតទៅទៀត ?
៨-៣- តើអង្គការខេមរយានកម្មគ្រោងដំឡើងគុណភាព
សៀវភៅនិងពង្រីកឥទ្ធិពលសៀវភៅបែបណា ?

៩– លទ្ធផលនៃអនុវត្តន៍ខេមរយានកម្ម ៣៩
៩–១ តើគណៈកម្មការពិនិត្យនិងប្រមាណលទ្ធផលនៃអនុវត្តន៍ខេមរយានកម្មមានយោបល់យ៉ាងណា ?
៩–២– តើសាស្ត្រាចារ្យបង្រៀននៅមធ្យមសិក្សាមានយោបល់យ៉ាងដូចម្តេចចំពោះអនុវត្តន៍ខេមរយានកម្ម?
៩–៣– តើគណៈមេប្រយោគប្រលងមធ្យមសិក្សាប័ត្របឋមភូមិយល់ដូចម្តេច ?
៩–៤– តើការប្រលងមធ្យមសិក្សាប័ត្របឋមភូមិរបបខេមរយានកម្មជាលើកដំបូងផ្តល់លទ្ធផលបែបណា ?
១០– ខេមរយានកម្មនិងភាសាបរទេស ៥០
១១– ខេមរយានកម្មនិងអង្គការរដ្ឋធានា ៥២
១២– ខេមរយានកម្មនិងបតិសាធារណជន ៥៣

# ស្ថានភាពខេមរយានកម្មនៅមធ្យមសិក្សា

ដោយ

ឡុច ផ្លេង អគ្គលេខាធិការខេមរយានកម្ម

## សេចក្ដីផ្ដើម

ប្រទេសជាតិណាក៏ដោយ ឱ្យតែមានអរិយធម៌ជាតិជាមូលដ្ឋាន ជាទ្រព្យសម្បត្តិផ្ទាល់ តែងពេញចិត្តនឹងជាតិខ្លួនដរាប ហើយមិនញញើតនឹងស្នូកាឡៃអ្វីៗ ជាបរទេសឲ្យមានលក្ខណៈជាតិឡើងនោះឡើយ ។ រឿងស្នូកាឡៃបែបនេះ មាននៅគ្រប់វិស័យនៃអរិយធម៌ យ៉ាងណាមិញវិស័យវប្បធម៌ជាពិសេស វិស័យភាសានិងអក្សរសាស្ត្រ ក៏ជួបប្រទះនឹងការស្នូកាឡៃនេះដែរ ។

ប្រទេសខ្មែរយើង ចាត់ទុកជាប្រទេសមួយ ដែលបានទទួលឥទ្ធិពលបរទេសច្រើនគួរសមដែរ តាំងពីសម័យបុរាណមក ដូចជាឥទ្ធិពលនៃអរិយធម៌ឥណ្ឌា ចិន អឺរ៉ុប តាមរយៈកិច្ច

ការសាសនា ទូត ជំនួញ... ។ តាមនិយតភាពនៃទំនាក់ទំនង ពាក្យពេចន៍បរទេសខ្លាំងជាងគេ បាលី សំស្ក្រឹត ក៏បានចូលមកជាមួយ ហើយត្រូវខ្មែរស្ទកាឡៃ ឲ្យមកជាពាក្យខ្មែរ ឬ បែបខ្មែរទាំងអស់ ទាំងសូរ ទាំងរូប ទាំងន័យ ។

មិនត្រឹមតែពាក្យពេចន៍ប៉ុណ្ណោះទេ សូម្បីតែវិជ្ជានានាដូចជាវិជ្ជាសាសនា វិជ្ជាសំណង់ វិជ្ជាចំលាក់ ដែលបានទទួលមួយផ្នែកពីបរទេសក៏ត្រូវលើកយកមកបង្ហាត់បង្រៀនជាភាសាខ្មែរ ទើបមហាជនខ្មែរចេះយល់និងអនុវត្តបាន ។ បើនិយាយពីវិជ្ជាក្នុងស្រុកវិញនោះប្រាកដជាខ្មែររៀននិងបង្រៀនជាខ្មែរ។

មកដល់សម័យក្រោយមហានគរ ពោល គឺចាប់តាំងពីគ្រិស្តសតវត្សទី ១៥ មក ស្ថានការណ៍ច្របូកច្របល់នៃប្រវត្តិសាស្ត្រខ្មែរបណ្ដាលមកពីការដណ្ដើមអំណាចរដ្ឋរវាងរាជវង្សខ្មែរ បានអូសទាញប្រទេសខ្មែរឲ្យចូលទៅក្នុងកំរងអំណាចអាណានិគមនិយមបរទេសជិតឆ្ងាយរហូតទៅដល់ចំណុចមួយនៃប្រវត្តិសង្គមខ្មែរ ដែលយកភាសាបារាំងមកប្រើជាភាសាយានក្នុងការសិក្សា និងក្នុងកិច្ចការរដ្ឋបាលដែលជាគំណមានរហូតមកដល់សព្វថ្ងៃនេះ ។

មើលមួយត្រួសឡើងវិញ យើងឃើញថា តាំងពីសម័យកទឹកកដីខ្មែរមក ខ្មែរមានភាសាជាតិរបស់ខ្លួនមួយ សំរាប់

ប្រើការក្នុងគ្រប់វិស័យនៃអរិយធម៌ ប្រើខ្លាំងរហូតដល់ឲ្យថៃប្រើទៀត ហើយថៃប្រើរហូតមកដល់សព្វថ្ងៃនេះ ។ គឺជាគ្រោះថ្នាក់ដ៏សាហាវមួយ នៃប្រវត្តិសាស្ត្រខ្មែរ ដែលក្នុងសម័យអាណានិគមបារាំង ខ្មែរត្រូវអកក្រសបង្ខំខ្លួនឲ្យប្រើភាសាបារាំងជាផ្លូវការ ។ ទុកជាយ៉ាងដូច្នេះក៏ដោយ ឥទ្ធិពលនៃភាសាបារាំងពុំបានជ្រាបចូលដល់ស្រទាប់ជាន់ក្រោមនៃប្រជាជនខ្មែរឡើយ ។ នៅតាមវត្តអារាម ឃ្លាំងឧត្តមនៃវប្បធម៌ជាតិ និងមជ្ឈមណ្ឌលនៃភាតរភាពជាតិ និងនៃក្រុមជំនុំអ្នកប្រាជ្ញបណ្ឌិត កសិករ កម្មករ យុវជន យុទ្ធជន ប្រជាពលរដ្ឋខ្មែរ ខ្មែរនៅតែរៀន និងបង្រៀនភាសាជាតិ និងតាមរយៈភាសាជាតិដដែល ។

នេះនាំឲ្យយល់ឃើញថា យើងមានភាសា និងអក្សរជាតិមួយជាម៉ាស៊ីនសំរាប់កិនច្នៃភាសា និងអក្សរបរទេស ឲ្យមានលំនាំបែបខ្មែរ មិនតែប៉ុណ្ណោះសោត ភាសានិងអក្សរជាតិនេះ ក៏ចាត់ទុកជាកណ្ដៀវសំរាប់ច្រូតកាត់ប្រមូលចំណេះវិជ្ជាពីបរទេសមកទុកក្នុងជង្រុកជាតិ សំរាប់ផ្សព្វផ្សាយបន្តទៅប្រជាជាតិខ្មែរទាំងមូល ។

តាមលំនាំខាងលើនេះ ខ្មែរបានធ្វើខេមរយានកម្មជាយូរមកហើយចំពោះអ្វីៗជាបរទេស ហើយបានយកភាសាខ្មែរជា

យានក្នុងការរៀននិងបង្រៀនចំណេះវិជ្ជានានាពីបរទេស ។ ដូច្នេះ ខេមរយានកម្មពុំមែនជារឿងថ្មី មិនសមបើមកភ្ញាក់ផ្អើលត្រង់ខ្មែរធ្វើខេមរយានកម្ម ក្នុងការសិក្សានៅកណ្តាលសតវត្សទី ២០ នេះឡើយ ពីព្រោះយើងគ្រាន់តែតំរង់តំរឹមអ្វីៗដែលរប៉ាត់រប៉ាយឲ្យចូលគន្លងតែមួយដូចមុនតែប៉ុណ្ណោះ ។

## ១. ប្រវត្តិកំណើតអង្គការខេមរយានកម្ម

តទៅនេះជាប្រវត្តិកាលសំខាន់ៗនៃកំណាកំណើតអង្គការខេមរយានកម្ម :

– ១០ មិថុនា ១៩៦៧ : អង្គប្រជុំក្រុមប្រឹក្សាជាន់ខ្ពស់ នៃសកលវិទ្យាល័យនៃក្រសួងអប់រំជាតិ សំរេចបង្កើតគណៈកម្មការរៀបចំធ្វើខេមរយានកម្មក្នុងការសិក្សា

– ២០ មិថុនា ១៩៦៧ : ប្រជុំគណៈកម្មការរៀបចំខេមរយានកម្ម នៅសកលវិទ្យាល័យវិចិត្រសិល្បៈស្តីពីរឿងកិច្ចការដែលត្រូវធ្វើ រឿងធ្វើសៀវភៅនិយាយអំពីការរៀបចំធ្វើខេមរយានកម្ម ។

– ២៧ មិថុនា ១៩៦៧ : ប្រជុំគណៈកម្មការរៀបចំខេមរយានកម្មនៅសកលវិទ្យាល័យវិចិត្រសិល្បៈ ស្តីពីរឿងកិច្ចការដែលត្រូវធ្វើត និងរឿងគំរោងធ្វើព្រឹត្តិប័ត្រ។

– ០៥ កក្កដា ១៩៦៧ : សមាគមទាំងនេះផ្សាយ សេចក្ដីថ្លែងការណ៍រួម ក្នុងមហាសន្និបាតវិសាមញ្ញ ស្ដីពីរឿងប្រើភាសាខ្មែរជាយានក្នុងការសិក្សា ។

– ០៨ កក្កដា ១៩៦៧ : សមាគមសាស្ត្រាចារ្យខ្មែរចូលថ្វាយបង្គំសម្ដេចសង្ឃរាជ "ជួន ណាត" ដើម្បីទទួលព្រះឱវាទ ស្ដីពីរឿងប្រើភាសាជាតិ ។

– ១០ ដល់ ១៣ កក្កដា ១៩៦៧ : សមាជជាតិលើកទី ២៣ ដោយមានលោក ហ៊ែល ស៊ុំផា ជាម្ចាស់បញ្ញាស្នើឲ្យប្រើភាសានិងអក្សរខ្មែរក្នុងការសិក្សា និងក្នុងកិច្ចការរដ្ឋបាល បានសំរេចឲ្យប្រើភាសាខ្មែរជាទូទៅ ក្នុងកិច្ចការរដ្ឋបាលនិងការសិក្សា លើកលែងតែក្នុងវិស័យទាក់ទងជាមួយនឹងបរទេស ។

– ១៤ កក្កដា ១៩៦៧ : អង្គប្រជុំនៃអ្នកទទួលខុសត្រូវខាងអប់រំនៃក្រសួងអប់រំជាតិ បានសំរេចឲ្យអនុវត្តខេមរយានកម្មគ្រប់មុខវិជ្ជានៅមធ្យមសិក្សា នៅថ្នាក់ទី ៦ ចាប់ពីឆ្នាំ ១៩៦៧-៦៨ នេះទៅ ។

– ១៨ កក្កដា ១៩៦៧ : ប្រជុំគណៈកម្មការរៀបចំ ខេមរយានកម្ម នៅសកលវិទ្យាល័យវិចិត្រសិល្បៈ ស្ដីពីរឿងលទ្ធផល នៃសមាជនាយកគ្រឹះស្ថានមធ្យមសិក្សា

ឡើងពិធានការអនុវត្តខេមរយានកម្ម ឡើងសំណូមពរ
ចំពោះលោករដ្ឋមន្ត្រី ស្ដីអំពីអនុវត្តន៍ខេមរយានកម្ម
នោយក្នុងសិក្សា ។

– ០៥ សីហា ១៩៦៧ : ក្រសួងអប់រំជាតិ ចេញលិខិតបង្គាប់
ការលេខ ៥០៦ កន. ចុះថ្ងៃ ០៥.០៨.៦៧ បង្កើត
គណៈកម្មាធិការជាតិអចិន្ត្រៃយ៍ នៃខេមរយានកម្ម
សិក្សា ។

– ០៧ សីហា ១៩៦៧ : ក្រសួងអប់រំជាតិចេញលិខិតបង្គាប់ការ
លេខ ៥០៧ កន. ចុះថ្ងៃ ០៧.០៨.៦៧ បង្កើតគណៈ
កម្មការបច្ចេកទេសគណិតវិទ្យា រូបវិទ្យាគីមី ធម្មជាតិ
វិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា សកម្មភាពប្រតិបត្តិ ។

– ០៨ សីហា ១៩៦៧ : ប្រជុំគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃ
ខេមរយានកម្មនៅសកលវិទ្យាល័យវិចិត្រសិល្បៈស្ដី
ពីរឿងអនុវត្តន៍ខេមរយានកម្ម ។

– ២៦ សីហា ១៩៦៧ : សិក្ខាសាលា នៃបុគ្គលិកសិក្សាទាំង
អស់នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសកល
វិទ្យាល័យភ្នំពេញ ស្ដីពីរឿងអនុវត្តន៍ខេមរយានកម្ម
ក្នុងការសិក្សា ។

– ០២ កញ្ញា ១៩៦៧ : ក្រសួងអប់រំជាតិចេញលិខិតបង្គាប់ការ
លេខ ៥៩២ កន. ចុះថ្ងៃ ០២.០៩.៦៧ បង្កើតបន្ថែម

ទៀតនូវគណៈកម្មការបច្ចេកទេស វិជ្ជាមេផ្ទះ រោង ជាង កសិកម្ម ។

- ១៨ កញ្ញា ១៩៦៧ : ក្រសួងអប់រំជាតិចេញប្រកាស លេខ ២.២៩៤ ចុះថ្ងៃ ១៨.០៩.៦៧ បញ្ជាឲ្យអនុវត្តខេមរយានកម្មក្នុងមធ្យមសិក្សា ចេញពីថ្នាក់ទី ៦ ចាប់ពីបវេសនកាលសិក្សា ១៩៦៧ ៦៨ នេះទៅ ។
- ២៩ កញ្ញា ១៩៦៧ : ក្រសួងអប់រំជាតិចេញសារាចរ លេខ ២៩ កន. ចុះថ្ងៃ ២៩.០៩.៦៧ ឲ្យចាត់វិធានការចាំបាច់និងជាបន្ទាន់ចំពោះអនុវត្តន៍ខេមរយានកម្ម ព្រមជាមួយគ្នានេះ ក្រសួងអប់រំជាតិបានបង្កើតអគ្គលេខាធិការដ្ឋានខេមរយានកម្មមួយ ក្នុងផ្ទៃនៃគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្ម ដែលតាំងនៅសកលវិទ្យាល័យវិចិត្រសិល្បៈ ហើយឥឡូវនេះមកតាំងនៅត្រង់ផ្ទះលេខ ៣ ផ្លូវឧកញ៉ាម៉ែន ក្រុងភ្នំពេញ ។

រួមសេចក្ដីមក អង្គការខេមរយានកម្មបានចាប់កំណើតឡើង ដោយទឹកចិត្តឈឺឆ្អាលរបស់ប្រជាជាតិខ្មែរទាំងមូល ចំពោះភាសា និងអក្សរសាស្ត្រជាតិ ដែលចេះតែរោយរៀរទៅៗដោយសារសកម្ម

ភាពរាតត្បាតនៃភាសានិងអក្សរសាស្ត្របរទេស មានបារាំងនេះជាអាទិ៍ ។ ជាពិសេស គឺបុគ្គលិកសិក្សាខ្មែរនិងអ្នកទទួលខុសត្រូវខាងអប់រំនេះតែម្តង ដែលជាអ្នកដឹងរឿងនេះច្បាស់។

មែនទែនទៅ ខេមរយានកម្មគួរណាស់តែចាប់កំណើតកើតឡើងក្នុងពេលជាមួយគ្នានឹងកំណើតនៃឯករាជ្យជាតិ នៅឆ្នាំ ១៩៥៣ ឬយ៉ាងយូរណាស់ត្រឹម ៣ ឆ្នាំតមកទៀត តែពុំដូច្នោះទេ ខេមរយានកម្មនៅបឋមសិក្សាបានចាប់មានរូបរាង ១៤ឆ្នាំក្រោយឯករាជ្យជាតិ ហើយបើពុំបានកើតនៅឆ្នាំ ១៩៦៧ នេះទេ ខេមរយានកម្មក៏មិនសង្ឃឹមថានឹងមានវត្តមានក្នុងសិក្សាធិការជាតិខ្មែរឡើយ ។

ជាសេចក្តីសង្កេត គ្រាន់តែសំរេចភ្លាមឱ្យធ្វើភ្លាម យើងពុំមានពេលវេលាគ្រប់គ្រាន់សំរាប់រៀបចំគំរោងការ ឱ្យបានគ្រប់សព្វ ជាហេតុនាំឱ្យអនុវត្តន៍ខេមរយានកម្មជួបប្រទះនឹងឧបសគ្គច្រើន តែពុំមែនដល់ទៅពុះពារមិនរួចនោះទេ ។ ក្នុងសម័យនោះ មានមតិខ្លះលឿនខ្លាំងរហូតដល់ទៅថា ឱ្យធ្វើខេមរយានកម្មភ្លាម នៅបួនថ្នាក់នៃមធ្យមសិក្សាបឋមភូមិតែម្តង ខ្លះលឿនល្មមថា ឱ្យធ្វើមួយឆ្នាំពីរថ្នាក់ៗ តែមតិអ្នកប្រុងប្រយ័ត្នបានស្នើសុំទៅម្តងមួយថ្នាក់ៗ ។

## ២. ទំរង់អង្គការខេមរយានកម្ម



## ទំរង់អង្គការអគ្គលេខាធិការដ្ឋានខេមរយានកម្ម

**អគ្គលេខាធិការដ្ឋាន (អគ្គលេខាធិការ)**

- **ការិយាល័យ រដ្ឋបាល (អគ្គលេខាធិការរង)**
  - ផ្នែកទាក់ទងសាធារណៈ
  - ផ្នែករបៀប និង កិច្ចការទូទៅ
  - ផ្នែកបុគ្គលិក
  - ផ្នែកគណនេយ្យ
  - ផ្នែកពាណិជ្ជកម្ម
  - ផ្នែកផ្សាយ និង ផ្ញើយថ្ង
- **ការិយាល័យរៀបបោះ (អគ្គលេខាធិការរង)**
  - ផ្នែកពិនិត្យអត្ថបទ
  - ផ្នែកកែវិញ្ញាសា
  - ផ្នែកគូររូប
  - ផ្នែករៀបទំព័រ

២ ១ មុខងារនៃអង្គការខេមរយានកម្ម

*អង្គការខេមរយានកម្មមានមុខងារសំខាន់ៗដូចតទៅ :*

មុខងារទី ១.– *អនុវត្តខេមរយានកម្មក្នុងការសិក្សា*

មុខងារទី ២.– ផ្សព្វផ្សាយចំណេះវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ទូទៅ ដោយប្រើអក្សរ និងភាសាខ្មែរ ។

មុខងារទី ៣.– រៀបរៀងបោះពុម្ព និង ផ្សព្វផ្សាយ ព្រឹត្តិប័ត្រ ទស្សនាវដ្តី សៀវភៅសិក្សា សៀវភៅវប្បធម៌ទូទៅ បែបខេមរយានកម្ម ។

មុខងារទី ៤.– ប្រមូលផ្តុំឯកសារស្រាវជ្រាវគ្រប់មុខវិជ្ជា ។

មុខងារទី ៥.– សិក្សាស្រាវជ្រាវអំពីអក្សរខ្មែរ ភាសាខ្មែរ ព្រម ទាំងវិជ្ជាឯកទេសនានា ដើម្បីជាមូលដ្ឋាននៃអនុវត្តន៍ ខេមរយានកម្ម ។

មុខងារទី ៦.– ទាក់ទង និង ប្តូរលទ្ធផលសិក្សាស្រាវជ្រាវ នៃ វិជ្ជាឯកទេសនានាជាមួយនឹងអង្គការជាតិ និងអន្តរ ជាតិដែលបានសមត្ថកិច្ចដូចគ្នា ។

២ ២.– គណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្ម: មានមុខ ងារពិភាក្សា និង ដឹកនាំដំណើរអនុវត្តខេមរយាន កម្មតាមបន្ទាត់នយោបាយសំខាន់ៗរបស់ក្រសួងអប់រំ ជាតិ ក្នុងក្របខ័ណ្ឌសិក្សាអប់រំ ។

២ ៣ អគ្គលេខាធិការដ្ឋាន : មានមុខងារញាំងកិច្ចការរដ្ឋបាល និង កិច្ចការបច្ចេកទេសរបស់អង្គការឲ្យមានដំណើរ ប្រព្រឹត្តទៅស្រួល (មើលចំរង់អង្គការ) ។

២.៤. គណៈកម្មាធិការពិសេសៈមានមុខងារពិគ្រោះដោះស្រាយបញ្ហាពិបាកៗ ក្នុងវិស័យកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាន ។

២.៥. គណៈកម្មការបច្ចេកទេសៈមានមុខងារពិសេសខាងកិច្ចការបច្ចេកទេស គឺរកពាក្យគន្លឹះ តាក់តែងមេរៀនចងក្រងជាសៀវភៅ ក្នុងសហការនឹងអគ្គលេខាធិការដ្ឋាន។

## ៣. មូលហេតុនៃកំណើតខេមរយានកម្ម

អស់រយៈ ១០ ឆ្នាំក្រោយសម័យឯករាជ្យមក សិក្សាធិការខ្មែរបានដំណើរថយក្រោយច្បាស់ ។ ការផ្តល់ចំណេះវិជ្ជាទៅសិស្ស ការទទួលចំណេះវិជ្ជាពីគ្រូ មានសភាពមិនមាំទាំហាក់ដូចជាចាប់ផុតៗ ។ ស្ថានការណ៍ល្អេងល្អោងនេះមានមូលហេតុមួយចេញមកពីការប្រើភាសាបារាំង ក្នុងការសិក្សាព្រោះមានគ្រូភាគខ្លះចេះភាសាបរទេសនោះមិនស្ទាត់ យល់ដែរ តែនៅស្រពេចស្រពិល ដូច្នេះសិស្សដែលរៀនវិជ្ជាបន្តពីគ្រូមកទៀតរឹតតែមិនច្បាស់ទៅទៀត ។ ប្រសិនជាយើងទុកស្ថានភាពនេះឲ្យមានតទៅទៀត យើងឃើញថា សិស្សរករៀនយកភាសាណាមួយឲ្យស្ទាត់ជំនាញមិនបាន ខ្មែរក៏មិនចេះបារាំងក៏មិនចេះ ។ ដោយស្រឡាញ់ភាសាបរទេសពេកទៅ

អ្នកនិយាយភាសាបរទេស ក៏តាំងបង្អាប់បន្តុះភាសាជាតិឯង បង្អាប់អ្នកណាដែលយកចិត្តទុកដាក់ នឹង ភាសាជាតិឯងទៅវិញ ។ នៅក្នុងផ្នែករដ្ឋបាលគេនិយាយថា អ្នកចេះបារាំងច្រើន ដូចជាគ្រាន់តែចេះ សរសេររបាយការណ៍ជាបារាំងក៏ដោយ គេចាត់ទុកអ្នកនោះជាវរជនជាអ្នកចេះធ្វើការដែរ ពោលឱ្យខ្លីទៅ គេនិយមយកភាសាបរទេសជាធំ គ្មានយកចំណេះវិជ្ជាឯកទេសអ្វីឡើយ ។ ដោយយកបញ្ហានេះមកគិតមើល យើងអាចឃើញថា នៅថ្ងៃណាមួយមិនខាន នឹងមានការបាក់បែកគ្នាក្នុងសង្គមដោយសារតែឥទ្ធិពលភាសាជាមិនខាន ។

ជាមួយនឹងស្ថានការណ៍នេះ នៅបឋមសិក្សា គេសង្កេតឃើញមានអនុវត្តន៍ខេមរយានកម្មរួចមកហើយ ហើយបានជោគជ័យពេញលេញ ។ កាលពីដំបូង គេមិនចង់អនុវត្តតាមខេមរយានកម្មនៅបឋមសិក្សាឡើយ តែស្ថានការណ៍បង្ខំគេទៅវិញ ព្រោះនៅបឋមសិក្សា គេពុំអាចយកបារាំងជាភាសាយានតទៅទៀតបាន ដោយយើងខ្វះខាតគ្រូជំនាញៗខាងភាសាបារាំង ។ ការដែលសិស្សខ្សោយបារាំងតាំងពីបឋមសិក្សានេះ ក៏ជាកត្តាមួយដែលពុំអាចឱ្យសិស្សយកភាសានេះជាភាសាយាននៅមធ្យមសិក្សា ។ ម្យ៉ាងទៀត នៅមធ្យមសិក្សា សិស្សក៏មិនចំណាប់ស្រាប់ បន្ថែមទៅលើគ្រូ

មិនជុំនាញទៅទៀត យើញថា យើងត្រូវតែបន្តខេមរយានកម្មទៅបញ្ចប់សិក្សាទៀត ។ ដោយមានការតឹងចិត្តនឹងរឿងវាសនារបស់កូនខ្មែរតូចតាច ដែលមិនអាចមានលុយកាក់ទៅរៀនសាលាបារាំងនឹងគេ មតិមហាជនបានផ្ទុះឡើងតាមសំលេងសមាជជាតិលើកទី ២៣ សំរេចឲ្យប្រើភាសាខ្មែរជាភាសាយាននៅមធ្យមសិក្សាទៀត ។

យើងចាប់អនុវត្តខេមរយានកម្ម ដោយយើងសង្កេតឃើញថា ប្រទេសជិតខាងយើងដែលកំពុងលូតលាស់ អាចយកភាសាជាតិគេមកប្រើក្នុងផ្នែករដ្ឋបាល និង ក្នុងការសិក្សាបាន ។ នៅតាមក្រុងនានាក្នុងស្រុកយើង គេសង្កេតឃើញតែអក្សរចិន និង អក្សរបារាំង ហាក់ដូចជាពុំមែនក្រុងរបស់ខ្មែរ បើទុកស្ថានការណ៍នេះឲ្យមានតទៅទៀត ឃើញថាវប្បធម៌ និងអរិយធម៌ខ្មែរមុខជាសាបសូន្យថ្ងៃណាមួយមិនខាន ។ អនុវត្តន៍ខេមរយានកម្មនៅប្រទេសយើងគ្មានការអ្វីឲ្យលំបាកខ្លាំងក្លាទេ ព្រោះអ្នកស្រុកស្ទើរតែ ១០០ % និយាយតែភាសាខ្មែរ ហើយបើយើងយកភាសាខ្មែរមកប្រើជាផ្លូវការមិនកើត យើងត្រូវខ្មាស សៀម យួន ពិសេសម៉ាឡាយូ ដែលមានភាសារហូតដល់ទៅបី គឺ ភាសា ម៉ាឡាយូ ចិន និងទមិឡ តែគេនៅតែចាត់វិធានការយកភាសាជាតិគេមកប្រើជាភាសាយានក្នុងការសិក្សាគ្រប់ភូមិសិក្សា ។

សំខាន់ជាងអ្វីៗទៅទៀត ប្រជាជាតិខ្មែរដែលកំពុងស្រេកឃ្លានសេចក្ដីចំរើនល្អលាស់ ខាងផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ព្រមទាំងផ្នែកវប្បធម៌ទៅ ត្រូវការជាចាំបាច់នូវចំណេះចេះដឹង ហើយនឹងទទួលចំណេះចេះដឹងទាំងនេះបាន លុះត្រាតែប្រើមធ្យោបាយភាសា និងអក្សរខ្មែរជាយាន ពីព្រោះយើងគ្មានមធ្យោបាយឯណា ទៅបង្ហាត់បង្រៀនប្រជាពលរដ្ឋទាំងនោះឲ្យចេះភាសាបរទេសទាំងអស់គ្នាទេ ។ បើនៅតែបណ្ដោយឲ្យបញ្ញវន្តមួយភាគ ដែលចេះភាសាបរទេសក្រសោបចំណេះ ដែលបានទទួលតាមរយៈភាសាបរទេសនោះទុកតែម្នាក់ឯង និងប្រើតែក្នុងក្រវល់គ្នាឯងក្នុងការសិក្សាក៏ដូចជាក្នុងកិច្ចការរដ្ឋបាល ប្រជារាស្ត្រតូចតាចគ្មានភ័ព្វសំណាងនឹងចេះដឹងអ្វីនឹងគេឡើយ ។ ស្ថានការណ៍អាសន្នបែបនេះប្រាកដជាខ្លាស់នឹងការកង់វិវត្តន៍នៃប្រវត្តិសង្គម ។

## ៤. ប្រយោជន៍នៃអនុវត្តន៍ខេមរយានកម្ម

តើអនុវត្តន៍ខេមរយានកម្មផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

៤ ១ ក្នុងវិស័យចិត្ត-គរុកោសល្យ

– ខេមរយានកម្ម ជួយសម្រួលការសិក្សារបស់សិស្ស ឲ្យឆាប់យល់ ឆាប់ចេះនូវសាច់វិជ្ជាដោយចៀសវាង ការទន្ទេញចាំមាត់ដោយឥតយល់ ។

– ខេមរយានកម្ម ជួយសម្រួលការបង្រៀនរបស់គ្រូ និងសាស្ត្រាចារ្យឲ្យផ្តល់លទ្ធផលឆាប់ ដោយមិនចាំបាច់ដើរវាងតាមរយៈភាសាបរទេស ។

៤-២- ក្នុងវិស័យអប់រំមហាជន

– ខេមរយានកម្ម ជួយញ៉ាំងវិធីអប់រំតាមផ្លូវកាយ វាចា ចិត្ត បញ្ញាឲ្យប្រព្រឹត្តទៅដោយងាយនិងដោយត្រង់ ។

– ខេមរយានកម្ម ជួយពង្រឹងចិត្តជាតិនិយមរបស់យុវជនខ្មែរ ដែលជាសសរគ្រឹះរបស់ប្រទេសជាតិ ។

៤-៣ ក្នុងវិស័យវប្បធម៌

– ខេមរយានកម្ម ដាស់ស្មារតីប្រជាជាតិខ្មែរ ឲ្យស្រឡាញ់ភាសា និងអក្សរខ្មែរ កេរដំណែលដ៏ថ្លៃថ្លារបស់បុព្វជនជាតិយើង ។

- ខេមរយានកម្ម ជួយបង្កើនពង្រីកវប្បធម៌ជាតិតាមរយៈសៀវភៅសរសេរជាអក្សរខ្មែរ ។

៤-៤- ក្នុងវិស័យសេដ្ឋកិច្ច

- ខេមរយានកម្ម ជួយពង្រីកផលិតកម្ម និងពាណិជ្ជកម្មសៀវភៅជាភាសាខ្មែរ ។

ខេមរយានកម្ម ជួយរដ្ឋមិនឲ្យចំណាយរូបិយប័ណ្ណទៅជួលសាស្ត្រាចារ្យបរទេស ឲ្យមកបង្រៀននៅបញ្ចប់សិក្សានូវមុខវិជ្ជាដែលខ្មែរបង្រៀនបាន ។

៤-៥- ក្នុងសង្គមកិច្ច

- ខេមរយានកម្ម ជួយរក្សាមុខរបរកម្មករខ្មែរក្នុងរោងពុម្ពនិងបណ្ណាគារឲ្យនៅគង់វង្ស ។

- ខេមរយានកម្ម ជួយបណ្តុះគំនិតតែងនិពន្ធ ដែលជាមុខរបរសំខាន់មួយសំរាប់ពង្រីកវប្បធម៌ជាតិ ។

៤-៦- ក្នុងវិស័យនយោបាយ

- ខេមរយានកម្ម ជួយពង្រីកជំហរឯករាជ្យជាតិដោយបង្កើតឲ្យមានឯករាជ្យវប្បធម៌ ។

- ខេមរយានកម្ម ជួយតំកើងកិត្យានុភាពជាតិដោយញាំងបរទេស ឲ្យមានចំណាប់អារម្មណ៍លើវប្បធម៌ខ្មែរកាន់តែខ្លាំងឡើង ។

– ខេមរយានកម្ម ជាដំរផ្សារសាមគ្គីជាតិដែលជាអវាវុធការពារជាតិ ។

– ខេមរយានកម្ម ញាំងប្រជារាស្ត្រ រដ្ឋការនិងព្រះសង្ឃឲ្យចូលជិតគ្នាដោយប្រើភាសាជាតិក្នុងការសរសេរ និងឆ្លើយឆ្លង ។

– ខេមរយានកម្ម ជាមជ្ឈមណ្ឌលប្រមូលផ្តុំបញ្ញវន្តខ្មែរដែលត្រឡប់មកពីសិក្សានៅបរទេសផ្សេងៗ ខុសសាសន៍គ្នាឲ្យប្រើភាសានិងអក្សរខ្មែរតែមួយ សំរាប់ផ្ទេរចំណេះវិជ្ជាទៅសិស្ស និស្សិត និងមហាជន ហើយនិងសំរាប់បំរើកិច្ចការអភិវឌ្ឍន៍ប្រទេសជាតិក្នុងឯកភាពនៃភាសានិងអក្សរខ្មែរ ។

## ៥. មធ្យោបាយនៃអនុវត្តន៍ខេមរយានកម្ម

ដើម្បីធ្វើការអ្វីមួយឲ្យបានសំរេចដោយជោគជ័យ គេត្រូវមានមធ្យោបាយគ្រប់គ្រាន់ និងកំលាំងចិត្តខ្លាំងក្លា ។

តើខេមរយានកម្មមានមធ្យោបាយគ្រប់គ្រាន់ឬទេ ?

### ៥ ១- បុគ្គលិក

បួនឆ្នាំដំបូងនៃអនុវត្តន៍ខេមរយានកម្មខ្វះខាតបុគ្គលិកច្រើន តែឥឡូវនេះបញ្ហានេះចោទដែរតែមិនតឹងដូច

មុនតែនឹងចោទឡើងវិញ នៅពេលដែលខេមរយានកម្មពង្រីកសកម្មភាពរបស់ខ្លួនតាមគំរោងនៃវិទ្យាស្ថានជាតិខេមរយានកម្ម ។

៥-១- អ្នកនិពន្ធ

នៅមធ្យមសិក្សាបឋមភូមិ បញ្ហាអ្នកនិពន្ធមិនសូវចោទប៉ុន្មាន ពីព្រោះយើងសំបូរសាស្ត្រាចារ្យគួរសម ដែលបានមួយភាគជាសមាជិកគណៈកម្មការបច្ចេកទេសមានភារៈនិពន្ធមេរៀនតែម្តង ។ គឺគណៈកម្មការបច្ចេកទេស ជាផលិតករមេរៀនទៅតាមមុខវិជ្ជាដែលត្រូវការ ។ ដល់ខេមរយានកម្មចូលដល់មធ្យមសិក្សាទុតិយភូមិ យើងត្រូវការសាស្ត្រាចារ្យបរិញ្ញាប័ត្រ និងបណ្ឌិតប័ត្រដែលខ្មែរយើងខ្វះ សំរាប់ឲ្យមកជួយតាក់តែងមេរៀន ។ ទុកជាយ៉ាងដូច្នេះក៏ដោយ យើងនៅតែជឿជាក់ថាខេមរយានកម្មនឹងប្រព្រឹត្តទៅ ដោយរលុះរលាញរហូតដល់ចប់មធ្យមសិក្សា អាស្រ័យលើពលិកម្មដ៏ស្មោះស្ម័គ្រនៃសមាជិក គណៈកម្មការបច្ចេកទេសដែលយើងមាន ។

### ៥-៣ - ប្រាក់

ប្រាក់ជាមធ្យោបាយសំខាន់ណាស់ ។ គឺព្រោះតែគ្មានប្រាក់នេះហើយ បានជាខេមរយានកម្មប៉ះមុខប៉ះក្រោយទន្ទេមទន្ទោម ។ កាលសម័យនោះអតីតប្រមុខរដ្ឋខ្មែរ យល់ស្របឱ្យធ្វើខេមរយានកម្មតែបំបិទមធ្យោបាយគ្រប់ច្រក ដោយបញ្ជាក់ហើយបញ្ជាក់ទៀតថា ធ្វើខេមរយានកម្មចុះកុំឱ្យតែប៉ះពាល់ថវិកាជាតិ ។ ឮដូច្នេះ ទីស្តីការដ្ឋមន្ត្រីអប់រំជាតិក្នុងសម័យនោះរួញខ្លួន មិនបានជួយអ្វីម៉្មោះហើយអ្នកដែលត្រូវទទួលបញ្ជាហើយខ្វះមធ្យោបាយ ខំច្នៃច្នកថែរទៅតាមលទ្ធភាពដែលខ្លួនបាន តែគ្មានងប៉ុន្មាននាក់នោះទេ ។ ទើបមកដល់បីឆ្នាំចុងក្រោយនេះ ក្រសួងអប់រំជាតិ និង ក្រសួងហិរញ្ញវត្ថុចាប់ជួយបណ្តើរ ជាឥណទានសំរាប់បោះពុម្ពសៀវភៅ ហើយសំរាប់ឱ្យខេមរយានកម្មទុកជាទុនបង្វិលបោះពុម្ពសៀវភៅថ្មីៗទៅទៀត ។

### ៥ ៤ សម្ភារៈ និងអគារ

ដោយពុំបានរៀបចំទុកជាមុន តាមគំរោងការជាក់លាក់ អង្គការខេមរយានកម្មខ្វះខាតសម្ភារៈប្រើ

ប្រាស់គ្រប់សព្វ ចាប់តាំងពីតុ កៅអីទៅ ក៏ប៉ុន្តែដោយមានសេចក្ដីយោគយល់ និងដឹងទុក្ខធុរៈ សកលវិទ្យា-ល័យវិចិត្រសិល្បៈ បានផ្ដើមធ្វើអំណោយសម្ភារៈជាច្រើនជូនចំពោះអង្គការខេមរយានកម្ម ប្តូររួមទាំងទីកន្លែងសំរាប់អគ្គលេខាធិការដ្ឋានធ្វើការផង ។ បន្ទាប់មកទៀត ខេមរយានកម្មបានទទួលអំណោយជា តុ ទូ កៅអី ពីនាយកដ្ឋានកិច្ចការគរុកោសល្យ ជាតិបន្ទីវិធានផែនការអប់រំជាតិ នាយកដ្ឋានមធ្យមសិក្សា មហាវិទ្យាល័យគរុកោសល្យ ។ល។ ឥឡូវនេះ ក្រសួងបានផ្ដល់អគារមួយ លេខ ៣ ផ្លូវខកញ៉ាម៉ែនសំរាប់អគ្គលេខាធិការដ្ឋាន ។

ជាចុងក្រោយ ពាក្យគន្លឹះ មេរៀន ទស្សនាវដ្ដី ព្រឹត្តិប័ត្រសៀវភៅនៃអង្គការខេមរយានកម្ម ក៏ចាត់ទុកជាមធ្យោបាយមូលដ្ឋានសំរាប់អនុវត្ត និងផ្សាយខេមរយានកម្ម ដែលនឹងមានបរិយាយយ៉ាងពិស្តារតទៅក្រោយទៀត ។

## ៦. ដំណើរនៃអនុវត្តន៍ខេមរយានកម្មនៅមធ្យមសិក្សា

### ៦ ១- ដំណាក់នៃអនុវត្តន៍

| | | | |
|---|---|---|---|
| ឆ្នាំ | ១៩៦៧-៦៨ | : | ថ្នាក់ទី ៦ |
| ឆ្នាំ | ១៩៦៨-៦៩ | : | - ៥ |
| ឆ្នាំ | ១៩៦៩-៧០ | : | - ៤ |
| ឆ្នាំ | ១៩៧០-៧១ | : | - ៣ |

ឆ្នាំ ១៩៧១-៧២ : - ២

ឆ្នាំ ១៩៧២-៧៣ : - ១

ឆ្នាំ ១៩៧៣-៧៤ : - បញ្ចប់

តាមគំរោងអនុវត្តនេះ យើងឃើញថា :

នៅចុងឆ្នាំ ១៩៧០ ៧១ មានសិស្សជាប់មធ្យមសិក្សាប័ត្របឋមភូមិ របបខេមរយានកម្មជាលើកដំបូង ។

នៅចុងឆ្នាំ ១៩៧២-៧៣ នឹងមានសិស្សជាប់មធ្យមសិក្សាប័ត្រភាគទី ១ របបខេមរយានកម្មជាលើកដំបូង ។

នៅចុងឆ្នាំ ១៩៧៣-៧៤ នឹងមានសិស្សជាប់មធ្យមសិក្សាប័ត្រភាគទី ២ របបខេមរយានកម្មជាលើកដំបូង ។

នៅដើមឆ្នាំ ១៩៧៤ ៧៥ ខេមរយានកម្មនឹងចូលដល់ឧត្តមសិក្សាជាលើកដំបូង ។

តាមសង្កេតទៅ ខេមរយានកម្មនៅឧត្តមសិក្សាមានពេលរៀបចំយូរដល់ទៅ ៧ ឆ្នាំ ។ បានជាថាយូរដូច្នេះ ព្រោះកាលបើដឹងថា ខេមរយានកម្មចាប់អនុវត្តនៅមធ្យមសិក្សា ឧត្តមសិក្សាត្រូវរៀបដើងព្រួលឡូស្រេចទៅ ថាគង់តែជួបបញ្ហានេះហើយ ។ បើទុកជាថ្ងោះធ្លោយមិនបានគិតទុកដល់ទៅ ៧ ឆ្នាំ ឧត្តមសិក្សាក៏គង់នៅមានភ័ព្វវាសនាសល់ពេល ២ ឆ្នាំទៀតដែលសំរាប់រៀបចំ មិនកញ្ចក់កណ្តៀតដូចមធ្យមសិក្សាដែលសំរេចក្តាមធ្វើភ្លាមតែម្តង ។

## ៦-២- តារាងកំរិតម៉ោងសិក្សាប្រចាំសប្តាហ៍នៅមធ្យមសិក្សា

| មុខវិជ្ជា | បឋមភូមិ | | | | | | ទុតិយភូមិ | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | បញ្ចប់ | | |
| | ទី ៦ | ទី ៥ | ទី ៤ | ទី៣ | ទី២ | ទី ១ | ទស្សនវិជ្ជា | គណិតវិទ្យា | វិទ្យាសាស្ត្រ |
| ១ ខ្មែរ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ០ | ០ | ០ |
| ២ ភាសាបរទេសទី ១ | ៨ | ៨ | ៧ | ៧ | ៦ | ៦ | ៧ | ៥ | ៥ |
| ៣ ភាសាបរទេសទី ២ | ០ | ០ | ០ | ០ | ៣ | ២ | ៣ | ២ | ២ |
| ៤ ប្រវត្តិវិទ្យា-ភូមិវិទ្យា | ២ | ២ | ២ | ២ | ២ | ២ | ៤ | ២ | ២ |
| ៥ ទស្សនវិជ្ជា | ០ | ០ | ០ | ០ | ០ | ០ | ៨ | ៣ | ៣ |
| ៦ពលរដ្ឋវិជ្ជា-សីលវិជ្ជា | ១ | ១ | ១ | ១ | ១ | ១ | ០ | ០ | ០ |
| ៧ គណិតវិទ្យា | ៤ | ៤ | ៤ | ៤ | ៥ | ៦ | ២ | ៨ | ៦ |
| ៨ រូបវិទ្យា-គីមី | ២ | ២ | ៣ | ៣ | ៥ | ៥ | ២ | ៦ | ៦ |
| ៩ ធម្មជាតិវិទ្យា | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ៤ |
| ១០ សកម្មភាពប្រតិបត្តិ | ៤ | ៤ | ៥ | ៥ | ០ | ០ | ០ | ០ | ០ |
| ១១ គំនូរ-សិល្បៈ | ១ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១២ អប់រំកាយ-កីឡា | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ | ២ |
| សរុប | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ |

## ៧. ពាក្យគន្លឹះខេមរយានកម្ម

៧.១– អ្វីទៅពាក្យគន្លឹះ ?

ដើម្បីរៀបចំបេរៀន អ្នកនិពន្ធត្រូវការជាចាំបាច់នូវពាក្យបច្ចេកទេស ដែលជាកូនសោសំខាន់ទៅចាក់ចំលងយកចំណេះ ។ វិជ្ជាមួយមុខៗ តែងតែមានពាក្យគន្លឹះរបស់ខ្លួនជាដរាប ហើយគេមិនចេះតែយកទៅប្រើជាទូទៅស្រេចតែចិត្តនោះឡើយ ។ ចាប់ធ្វើខេមរយានកម្មភ្លាម យើងសំរុកកំលាំងគ្នាទៅលើកិច្ចការបកប្រែពាក្យគន្លឹះ ពីព្រោះពាក្យខ្មែរបច្ចុប្បន្នមានចំនួនមិនគ្រប់គ្រាន់ សំរាប់ប្រើប្រាស់ក្នុងវិជ្ជាទំនើបឡើយ សូម្បីតែប្រទេសជឿនលឿនខាងវិទ្យាសាស្ត្របច្ចេកទេសទៅហើយក៏ដោយ នៅតែត្រូវបង្កើតពាក្យគន្លឹះថ្មីៗ សំរាប់ប្រើក្នុងសាខាវិជ្ជាទំនើបៗដែរ ។

៧–២– តើអនុម័តពាក្យគន្លឹះផ្អែកទៅលើគោលការណ៍អ្វីខ្លះ ?

គោលការណ៍ច្បងៗគឺ

៧–២–១–បកឱ្យមកជាខ្មែរ : នេះជាគោលការណ៍សំខាន់ត្រូវចំណុចចិត្តខេមរយានកម្មតែម្តង ។ ខេមរយានកម្ម

បានយកក្បួនបង្កើតពាក្យខ្មែរ តាមពាក្យឧទាហរណ៍នានាស្រង់ចេញពីភាសាខ្មែរប្រើប្រាស់គ្រប់សម័យកាល ។ បើរកពាក្យខ្មែរសុទ្ធមិនបាន យើងរត់ទៅរកពាក្យបាលី សំស្ក្រឹតងាយៗ ដែលធ្លាប់ប្រើរួចមកហើយ ងាយទាំងសូរ ងាយទាំងអក្ខរាវិរុទ្ធ ដោយចៀសវាងជាដាច់ខាត នូវពាក្យបាលី សំស្ក្រឹតពិបាកៗ ។

៧-២-២- បកឱ្យងាយប្រើ : ខេមរយានកម្មប្រកាន់យកអាកប្បកិរិយាមួយគឺ មិនទុកភាសាជាបំណងចុងក្រោយបំផុតនៃការសិក្សា តែទុកភាសាជាយានជាមធ្យោបាយ ជាតំពក់ទៅថ្លក់បេះយកចំណេះវិជ្ជាឱ្យបានឆាប់រហ័ស ដូច្នេះមិនត្រូវធ្វើភាសាឱ្យពិបាក ។ បើចង់ឱ្យភាសាខ្មែរមានភាពងាយស្រួល ត្រូវសំរួលតាំងពីពាក្យពេចន៍ ឃ្លាប្រយោគទៅពោលគឺសរសេរពាក្យឱ្យងាយ ប្រើឃ្លាប្រយោគឱ្យខ្លី មិនរញ៉េករញ៉ៃដោយវេវចនៈស្មុគស្មាញ ។

៧-២-៣- បកឱ្យស៊ីនឹងចំលាប់ : ពាក្យណាបានហើយ ប្រើស្រួលមាត់ហើយ យល់ទាំងអស់គ្នាហើយ យើង

ទុកប្រើតទៅទៀត ដោយរកគន្លឹះបន្សីគ្នានឹងពាក្យបរទេស ដូចជាពាក្យជាង ពាក្យសិល្បៈ ពាក្យធម្មជាតិវិទ្យាជាដើម ។

៧.២.៤. បកឱ្យមានឯកភាព : ក្បួនភាសាណាក៏ដូចជាភាសាណា ពិបាករកឯកភាពឱ្យបានស្អាតថែសបារាំងក៏ដូចខ្មែរ ខ្មែរក៏ដូចអង់គ្លេស ។ ទុកជាយ៉ាងដូច្នេះក៏ដោយ ក្នុងការងារបកប្រែ ខេមរយានកម្មខំរិះរកឯកភាពឱ្យបានច្បាស់លាស់គ្រាន់បើ ។

៧.២.៥. មិនបកពាក្យអន្តរជាតិ : ពាក្យបច្ចេកទេសក្នុងវិជ្ជាសំខាន់ៗដូចជាវិទ្យាសាស្ត្របច្ចេកទេសគណិតវិទ្យា រូបវិទ្យា-គីមី ធម្មជាតិវិទ្យា ភូមិវិទ្យាជាដើម មានមួយផ្នែកធំដែលខេមរយានកម្មមិនបក គឺទុកតាមសូរអន្តរជាតិទាំងស្រុង ( ដោយខ្មែរទទួលឥទ្ធិពលភាសាបារាំង យើងក៏គ្រាប់តាមសូរបារាំងជាអាទិភាព ) ដោយគ្រាន់តែសរសេរ ជាអក្សរខ្មែរប៉ុណ្ណោះ ។ មិនត្រឹមតែពាក្យអន្តរជាតិប៉ុណ្ណោះទេដែលយើងមិនបក សូម្បីតែនិមិត្តសញ្ញា ( symbole ) សញ្ញាសន្មត ( signe conventionnel ) រូបមន្ត ( formule ) ក៏ទុកនៅទាំងស្រុងតែម្តង ។

ជាសេចក្ដីសង្ខេប រឿងពាក្យគន្លឹះនេះមិនមែនថាគ្មានបញ្ហា ។ រឿងបកមិនទាន់ រឿងខ្វះឯកភាព រឿងផ្លាស់ប្ដូរ រឿងពាក្យថ្មីនាំឱ្យរាក់ សុទ្ធតែជាចំណោទដែលយើងមិនគេចថាមិនសារភាព ហើយដែលយើងកំពុងស្រាយជាមម៉ាញឹក ឱ្យទាន់តាមដំណើរវិវត្តវិទ្យាសាស្ត្រ បច្ចេកទេសពិភពលោក ក្នុងន័យថា ដើម្បីឱ្យល្អ ត្រូវតែច្នៃជាដរាប ។

៧. ៣. តើពាក្យគន្លឹះត្រូវអនុម័តឱ្យប្រើតាមរបៀបណា ?

ពាក្យគន្លឹះដែលខេមរយានកម្មប្រើ មានចែកជាច្រើនប្រភេទ :

- ពាក្យខ្មែរដែលខ្មែរប្រើយូរណាស់មកហើយតាមដំណើរវិវត្តនៃសង្គមខ្មែរ ។

- ពាក្យខ្មែរបង្កើតដោយគណៈកម្មការវប្បធម៌ដែលជាសាខាមួយនៃគណៈកម្មការជាតិខាងអប់រំ កើតពីឆ្នាំ ១៩៤៧ ក្រោមឱវាទក្រសួងអប់រំជាតិ ។

- ពាក្យខ្មែរបង្កើតដោយគណៈកម្មាធិការជាតិខេមរយានកម្ម កើតពីឆ្នាំ ១៩៦៧ ។

ចំពោះពាក្យគន្លឹះខេមរយានកម្មតើរបៀបបង្កើតពាក្យប្រព្រឹត្តទៅយ៉ាងណា ?

ដំណាក់ទី១ : គណៈកម្មការបច្ចេកទេស ស្រង់ពាក្យគន្លឹះជាបារាំងដេញទៅតាមមេរៀននិងទៅតាមថ្នាក់ហើយបកពាក្យបារាំងនេះ ជាខ្មែរផ្ញើស្នើមកគណៈកម្មការអនុម័តពាក្យ ក្នុងផ្ទៃនៃគណៈកម្មាធិការជាតិខេមរយានកម្ម ។

ដំណាក់ទី ២ : គណៈកម្មការអនុម័តពាក្យប្រកបដោយសមាជិកជាតំណាងមកពីគ្រប់គណៈកម្មការបច្ចេកទេសប្រជុំ ៣ ដងក្នុងមួយអាទិត្យ បានពិនិត្យពាក្យស្នើហើយអនុម័ត ។

ដំណាក់ទី៣ : អនុម័តរួចហើយ គណៈកម្មការអនុម័តពាក្យបានបញ្ជូនពាក្យអនុម័ត ទៅប្រគេនសម្តេចព្រះសង្ឃរាជ "ហួត តាត" ប្រធានគណៈកម្មការវប្បធម៌ទ្រង់ពិនិត្យនិងឡាយព្រះហស្តលេខាសំរេចឱ្យផ្សាយប្រើជាផ្លូវការទូទៅ ។

ជាសេចក្តីបញ្ជាក់ មុនថ្ងៃទី ០៨ ឧសភា ១៩៧២ គឺមុនថ្ងៃបង្កើតគណៈកម្មការអនុម័តពាក្យ របស់អង្គការខេមរយានកម្ម ពាក្យទាំងអំបាលម៉ានត្រូវបញ្ជូនទៅប្រគេនសម្តេចព្រះសង្ឃរាជ "ហួត តាត" ដែលព្រះអង្គ

ទ្រង់ពិនិត្យនិងអនុម័តតាមរយៈគណៈកម្មការវប្បធម៌ ហើយកាលដែលសម្ដេចសង្ឃរាជ"ជួន ណាត"ទ្រង់គង់ព្រះជន្មនៅឡើយ ពាក្យខេមរយានកម្ម ដែលត្រូវអនុម័តចេញពីគណៈកម្មការវប្បធម៌ហើយ ត្រូវដាក់ប្រគេនព្រះអង្គពិនិត្យ និងអនុម័តជាចុងក្រោយបង្អស់ ។

សព្វថ្ងៃនេះ ក្នុងបំណងរិះរកឯកភាពខាងពាក្យពេចន៍ និងភាសាខ្មែរ ក្រសួងអប់រំជាតិបានបង្កើតកាលពីថ្ងៃទី ២២ មេសា ១៩៧២ នូវគណៈកម្មការចំរុះខាងភាសាខ្មែរ ដែលមានតំណាងអង្គការខេមរយានកម្ម វិទ្យាស្ថានខ្មែរ-មន និងគណៈកម្មការវប្បធម៌ ផ្ដុំជាសមាសភាព ដើម្បីធ្វើការឡើងចុះសំរុងគ្នា ទំរាំតែបណ្ឌិតសភាខ្មែរ(១)ចាប់ដើរ ។

ដោយយល់ឃើញថា ពាក្យខេមរយានកម្មអនុម័តមិនទាន់សេចក្ដីត្រូវការក្នុងមុខវិជ្ជាខ្លះ អង្គការខេមរយានកម្មបានសំរេចថា ពាក្យណាបកមិនទាន់ហើយត្រូវការប្រើប្រញាប់ ត្រូវប្រើពាក្យនោះជាអក្សរបារាំងសិន ដូចសៀមនិងម៉ាឡាយូធ្វើ ។

(១) បណ្ឌិតសភាខ្មែរបានបង្កើតឡើងតាមក្រឹត្យលេខ ៤៩៩ CE ចុះថ្ងៃ២៥សីហា ១៩៦៥

៧.៤. ចំនួនពាក្យគន្លឹះ

ពាក្យគន្លឹះខេមរយានកម្ម ដែលបានអនុម័តប្រើមាន ដូចតទៅ :

ឆ្នាំទី ១ ដល់ទី ៤ (ចុង ១៩៦៧ ដល់ខែកក្កដា ១៩៧១)

—ចំនួនពាក្យផ្ដុំសរុប : ១១ ៦៤៨ ពាក្យ

—ចំនួនពាក្យរាយសរុប : ១៤ ៦៧១ ពាក្យ

ឆ្នាំទី ៥ (ខែសីហា ១៩៧១ ដល់ ខែមិថុនា ១៩៧២)

—ចំនួនពាក្យផ្ដុំសរុប : ១ ១២១ ពាក្យ

—ចំនួនពាក្យរាយសរុប : ១ ៤០៨ ពាក្យ

ឆ្នាំទី ១ ដល់ទី ៥

—ចំនួនពាក្យផ្ដុំសរុប : ១២ ៧៦៩ ពាក្យ

—ចំនួនពាក្យរាយសរុប : ១៦ ០៧៩ ពាក្យ

សង្កេត :– ពាក្យផ្ដុំសំគាល់កំរងពាក្យដែលអនុម័តរួមគ្នាតែម្ដង

ឧ– constante de raideur = ថេរកំរាញ (ពាក្យរូបវិទ្យា)

– germination épigée= ដំណុះទួលគ្រាប់ (ពាក្យធម្មជាតិវិទ្យា)

– ពាក្យរាយសំគាល់ ពាក្យទោលដែលអនុម័តតែឯងក្ដី ដែលដកទាញចេញពីពាក្យផ្ដុំក្ដី ។

១– lemme បទគន្លឹះ (ពាក្យគណិតវិទ្យា)

- raideur កំរាញ (ពាក្យរូបវិទ្យា)

épigé ទូលគ្រាប់ (ពាក្យធម្មជាតិវិទ្យា)

ជាសេចក្តីសង្ខេប ការងាររអនុម័តពាក្យនៅមានដំណើរវែងឆ្ងាយទៅមុខទៀត ។ ដោយពាក្យគន្លឹះជាមូលដ្ឋាននៃមធ្យមសិក្សាបកបានច្រើនណាស់មកហើយ អាចជួនល្មមនឹងការសិក្សាចំណេះវិជ្ជាទូទៅបានគ្រាន់បើ យើងយល់ថាពាក្យគន្លឹះនៅឧត្តមសិក្សាមិនសូវចោទជាបញ្ហាប៉ុន្មានឡើយ ពីព្រោះដល់ចូលខ្លាំងទៅក្នុងសាច់វិជ្ជាជាឯកទេសភាព ពាក្យគន្លឹះទាំងនោះ មិនត្រូវលើកយកមកបកឲ្យគ្រប់សព្វឡើយ គប្បីទុកឲ្យនៅគង់វង្សតាមអន្តរជាតិឲ្យបានច្រើន ។

## ៤. សៀវភៅខេមរយានកម្ម

សៀវភៅសិក្សាជាគោលដៅសំខាន់របស់អង្គការ ខេមរយានកម្ម ដែលត្រូវរត់ឲ្យទៅដល់ក្នុងអនាគតយ៉ាងខ្លីខាងមុខ។

ពិតណាស់សំដីដែលថា "តើធ្វើខេមរយានកម្មម្តេចកើត បើខ្វះសៀវភៅសិក្សាជាខ្មែរ" ។ ចំពោះសំដីនេះ យើងយល់ថា បើមិនធ្វើខេមរយានកម្មទេ សៀវភៅសិក្សាជាខ្មែរនៅ

តែគ្មាន ពីព្រោះគ្មានប្រយោជន៍នឹងទៅនិពន្ធសៀវភៅណាដែលគេមិនប្រើ ។ ដល់ខេមរយានកម្មកើតឡើង សៀវភៅសិក្សាជាខ្មែរស្រាប់តែបានលក់ផ្សាយព្រោងព្រាតទាំងរបស់រដ្ឋទាំងរបស់ឯកជន ហើយចេះតែបានកើតតទៅទៀត កាន់តែកើនច្រើន គុណភាពក៏កាន់តែល្អឡើង ដោយការប្រណាំងប្រជែង ។

ក៏ប៉ុន្តែធ្វើម្ដេច បើចេញដំណើរកញ្ជក់កណ្ដៀត ដំណើរនោះតែងតពិបតគុប ហើយអ្នកត្រួសត្រាយផ្លូវតែងមុតជង់ប៉ះបែកទង្គិច ច្រើនជាងអ្នកដើរក្រោយជាធម្មតា ។ យល់ច្បាស់នូវស្ថានភាពធម្មជាតិបែបនេះ យើងមិនញញើតនឹងទទួលពាក្យរិះគន់ទេ ។

ចំពោះរឿងសៀវភៅសិក្សានេះ អង្គការខេមរយានកម្មបានចាត់វិធានការដូចតទៅ :

បើមិនទាន់បានមេរៀនផ្សាយជាកូទៅទេសូមសាស្ត្រាចារ្យយកពាក្យគន្លឹះ ដែលមានទៅចងក្រងជាមេរៀនត្រាប់តាមសាច់វិជ្ជាដែលចេះដឹងបកហើយតាមភាសាបារាំង ។

-ផ្សាយមេរៀនតាមទស្សនាវដ្ដីខេមរយានកម្ម និងតាមព្រឹត្តិប័ត្រខេមរយានកម្មបណ្ដើរៗ ចំរាំតែចេញបានជាសៀវភៅពេញលេញ ។

វិធានការដែលចាត់ទៅនោះផ្តល់លទ្ធផលគួរសម ។ លទ្ធផលដែលពេញចិត្ត ដែលជាគោលដៅរបស់យើងគឺ សៀវភៅសិក្សា ។

៨.១. តើអង្គការខេបរយានកម្មផលិតបានសៀវភៅអ្វីខ្លះ ?

ថ្នាក់ទី ៦

| ឈ្មោះសៀវភៅ | លើក | ពុំលៃ | ចំនួន | ឆ្នាំចេញ |
|---|---|---|---|---|
| គណិតវិទ្យា | ទី១ | ៥០រ | ១០ ០០០ក្បា. | ១៩៦៨ |
| | ទី២ | ៦៥រ | ៥០០០ក្បា. | ១៩៧២ |
| | ទី៣ | ៨៥រ | ១០ ០០០ក្បា. | ១៩៧២ |
| រូបវិទ្យា-គីមី | ទី១ | ៣៥រ | ៥០០០ក្បា. | ១៩៦៩ |
| | ទី២ | ៤៥រ | ៩០០០ក្បា. | ១៩៧២ |
| ធម្មជាតិវិទ្យា | ទី១ | ៣៥រ | ៥០០០ក្បា. | ១៩៦៩ |
| ប្រវត្តិវិទ្យា | ទី១ | ៣០រ | ៦០០០ក្បា. | ១៩៦៨ |
| ភូមិវិទ្យា | ទី១ | ៤០រ | ៦០០០ក្បា. | ១៩៦៩ |

ថ្នាក់ទី ៥

| ឈ្មោះសៀវភៅ | លើក | តំលៃ | ចំនួន | ឆ្នាំចេញ |
|---|---|---|---|---|
| គណិតវិទ្យា ភាគ១ | ទី១ | ៥០ រ | ៧ ០០០ក្បា. | ១៩៦៩ |
| គណិតវិទ្យា ភាគ២ | ទី១ | ៤០ រ | ៧ ០០០ក្បា. | ១៩៧០ |
| គណិតវិទ្យា(រួមគ្នា) | ទី២ | ១២០ រ | ៥ ០០០ក្បា. | ១៩៧១ |
| រូបវិទ្យា-គីមី | ទី១ | ៦០ រ | ៧ ០០០ក្បា. | ១៩៧១ |
| ធម្មជាតិវិទ្យា | ទី១ | ៣២ រ | ៣០០០ក្បា. | ១៩៧១ |
| ប្រវត្តិវិទ្យា | ទី១ | ៨០ រ | ៤ ០០០ក្បា. | ១៩៧២ |
| ភូមិវិទ្យា | ទី១ | (បំរុងបោះពុម្ព) | | |

ថ្នាក់ទី ៤

| ឈ្មោះសៀវភៅ | លើក | តំលៃ | ចំនួន | ឆ្នាំចេញ |
|---|---|---|---|---|
| គណិតវិទ្យា | ទី១ | ១០០ រ | ១០០០០ក្បា | ១៩៧២ |
| រូបវិទ្យា-គីមី | ទី១ | ១១០ រ | ៦ ០០០ក្បា. | ១៩៧២ |
| ធម្មជាតិវិទ្យា | ទី១ | ១២៥ រ | ៤ ០០០ក្បា. | ១៩៧២ |
| ប្រវត្តិវិទ្យា | ទី១ | (បំរុងបោះ) | | |
| ភូមិវិទ្យា | ទី១ | (បំរុងបោះ) | | |

ថ្នាក់ទី ៣

| ឈ្មោះសៀវភៅ | លើក | តំលៃ | ចំនួន | ឆ្នាំចេញ |
|---|---|---|---|---|
| គណិតវិទ្យា | ទី១ | ៩៥ រ | ៦ ០០០ក្បា. | ១៩៧២ |
| | ទី២ | ១២០ រ | ១០០០០ក្បា. | ១៩៧២ |
| រូបវិទ្យា-គីមី | ទី១ | ៧០ រ | ៦ ០០០ក្បា. | ១៩៧១ |
| | ទី២ | ៩៥ រ | ១០០០០ក្បា. | ១៩៧២ |
| ធម្មជាតិវិទ្យា | ទី១ | ៦៥ រ | ៤ ០០០ក្បា. | ១៩៧១ |
| | ទី២ | ជិតចេញ | ៨ ០០០ក្បា. | ១៩៧២ |
| ប្រវត្តិវិទ្យា | ទី១ | ៥៥ រ | ៤ ០០០ក្បា. | ១៩៧១ |
| ភូមិវិទ្យា | ទី១ | ៨០ រ | ៤ ០០០ក្បា. | ១៩៧១ |

ថ្នាក់ទី ២ – ផ្សាយចេញជាព្រឹត្តិប័ត្រ តំលៃមួយក្បាល ៥រ

– ផ្សាយចេញនៅឆ្នាំ ១៩៧១-៧២

| ឈ្មោះព្រឹត្តិប័ត្រ | ចំនួនលេខ |
|---|---|
| គណិតវិទ្យា | ពីលេខ ១ ដល់លេខ ២៣ (ចប់) |
| រូបវិទ្យា | " ១៤ (ចប់) |
| គីមី | " ៩ (ចប់) |
| ធម្មជាតិវិទ្យា | " ៧ (មិនទាន់ចប់) |
| ប្រវត្តិវិទ្យា | " ៤ (មិនទាន់ចប់) |
| ភូមិវិទ្យា | " ១៣ (មិនទាន់ចប់) |
| ពាក្យគន្លឹះ | " ៤ (មិនទាន់ចប់) |

ថ្នាក់ទី ១

| ឈ្មោះសៀវភៅ | លើក | តំលៃ | ចំនួន | ឆ្នាំចេញ |
|---|---|---|---|---|
| គណិតវិទ្យា ភាគ១ | ទី១ | (កំពុងបោះ) | ១០ ០០០ក្បា | ១៩៧២ |
| រូបវិទ្យា : អគ្គិសនី និងអេឡិកត្រូម៉ាញេ | | | | |
| ទិកវិទ្យា | ទី១ | ១០០ ៛ | ៧ ០០០ក្បា. | ១៩៧២ |
| រូបវិទ្យា : អុបទិក | ទី១ | ១៦០ ៛ | ១០ ០០០ក្បា | ១៩៧២ |
| គីមី | ទី១ | ៤៨ ៛ | ១០ ០០០ក្បា | ១៩៧២ |
| ធម្មជាតិវិទ្យា ភាគ១ | ទី១ | ១៧៥ ៛ | ៦ ០០០ក្បា. | ១៩៧២ |
| ប្រវត្តិវិទ្យា ភាគ១ | ទី១ | ៣០ ៛ | ៦ ០០០ក្បា. | ១៩៧២ |
| ភូមិវិទ្យា ភាគ១ | ទី១ | ៥០ ៛ | ៦ ០០០ក្បា. | ១៩៧២ |

ថ្នាក់បញ្ចប់ :

សៀវភៅគ្រប់មុខកំពុងគ្រោងនិពន្ធ និងបោះពុម្ព ។

សៀវភៅផ្សេងៗ

| ឈ្មោះសៀវភៅ | លើក | តំលៃ | ចំនួន | ឆ្នាំចេញ |
|---|---|---|---|---|
| សព្ទានុក្រមបារាំង-ខ្មែរ ឆ្នាំទី១ | ទី១ | ៩០ ៛ | ១០០០០ក្បា. | ១៩៧០ |

| | | | | |
|---|---|---|---|---|
| គំនូរឧស្សាហកម្ម (ភាគ១) | ទី១ | ៣០ រ | ៣ ០០០ក្ប. | ១៩៦៩ |
| កីឡាបាល់បោះ | ទី១ | ៣៥ រ | ២ ០០០ក្ប. | ១៩៧២ |
| កីឡាកាយសម្ព័ន្ធ | ទី១ | ៤៨ រ | ៣ ០០០ក្ប. | ១៩៧២ |
| វិជ្ជាមេជួះ (ភាគ១) | ទី១ | (កំពុងបោះ) | ៣ ០០០ក្ប. | ១៩៧២ |

៨.២.តើអង្គការខេបរយានកម្មគ្រោងនឹងផលិតសៀវភៅអ្វីតទៅទៀត?

*ការងារខាងផលិតកម្មមានចែកជាប្រភេទដូចតទៅ*

ប្រភេទទី ១. *បោះពុម្ពឡើងវិញនូវសៀវភៅខេបរយានកម្មទាំងឡាយណាដែលបោះរួចហើយ ហើយដែលអស់ ។*

ប្រភេទទី ២. *បោះពុម្ពសៀវភៅខេបរយានកម្មទាំងឡាយទៅតាមមុខវិជ្ជាដែលមាននៅគ្រប់ថ្នាក់ នៃមធ្យមសិក្សា ហើយដែលពុំទាន់បោះសោះ ឬ ដែលបោះហើយ ប៉ែបព្រឹត្តិប័ត្រ ។*

ប្រភេទទី ៣. *បោះពុម្ពសៀវភៅសិក្សាសំរាប់បឋមសិក្សា បើមានកិច្ចព្រមព្រៀងគ្នានឹងនាយកដ្ឋានកិច្ចការ គរុកោសល្យ ។*

ប្រភេទទី៤. *បោះពុម្ពសៀវភៅវេយ្យាករណ៍ខ្មែរដែលជាគោល*

មូលដ្ឋាននៃភាសាខ្មែរ ។

ប្រភេទទី ៥.- បោះពុម្ព :

-សទ្ទានុក្រមខេមរយានកម្ម បារាំង-ខ្មែរ

-សទ្ទានុក្រមខេមរយានកម្ម ខ្មែរ-បារាំង

-វចនានុក្រមខេមរយានកម្ម ។

៨.៣ តើអង្គការខេមរយានកម្មគ្រោងដំឡើងគុណភាពសៀវភៅ និងពង្រីកឥទ្ធិពលសៀវភៅបែបណា ?

ជាធម្មតា អ្នកនិពន្ធតែងពេញចិត្តនឹងស្នាដៃរបស់ខ្លួនជាដរាប ហើយតែងទទួលស្គាល់ថា អ្វីដែលមិនប្រែប្រួលគឺហួសសម័យ ។ តាមទស្សនៈនេះ សៀវភៅគ្រប់មុខដែលផ្សាយចេញហើយ អ្នកនិពន្ធមិនដែលចាត់ទុកថាជាការស្រេចនោះទេ គេតែងតែច្នៃគុបតែងឲ្យមានគុណភាពខ្ពង់ខ្ពស់ឡើង តាមទាន់ចង្វាក់វិវត្តនៃពិភពលោក ទាំងខាងសាច់វិជ្ជា ទាំងខាងសាច់ក្រដាស ទាំងខាងរបៀបរៀបចំព័រ ទាំងខាងបច្ចេកទេសបោះពុម្ព ។ អាស្រ័យហេតុនេះហើយ បានជាអង្គការខេមរយានកម្មបញ្ជូនសមាជិករបស់ខ្លួនជានិច្ចទៅកាន់បរទេសដូចជា ជប៉ុន ម៉ាឡាយូ ថៃ ហ្វីលីពីន ស្រីលង្កា សិង្ហបុរី ជាដើម ដើម្បីធ្វើ

កម្មសិក្សា ទស្សនកិច្ច សិក្ខាសាលា ពិព័រណ៍ សន្និសីទ ស្ដីអំពីផលិតកម្មសៀវភៅនេះ ។ យើងសង្ឃឹមថា ទៅថ្ងៃមុខសៀវភៅខេមរយានកម្ម នឹងមានគុណភាពតាមកំរិតអន្តរជាតិជាពុំខាន ។

ម្យ៉ាងទៀត ក្នុងគោលបំណងយកភាសាខ្មែរជាភាសាយាន សំរាប់ផ្សព្វផ្សាយចំណេះវិជ្ជាសព្វសារពើឱ្យបានជ្រួតជ្រាបដល់មជ្ឈដ្ឋានមហាជន អង្គការខេមរយានកម្មប្រកាន់អាកប្បកិរិយាប្ដូយច្បាស់ថា នឹងខិតខំរក្សាតំលៃសៀវភៅខេមរយានកម្មឱ្យនៅថោក ប្រយោជន៍នឹងបំរើសេចក្ដីត្រូវការរបស់សិស្សនិងនិស្សិតខ្មែរ ។

## ៩. លទ្ធផលនៃអនុវត្តន៍ខេមរយានកម្ម

យើងរើផ្ទះចាស់មកនៅផ្ទះថ្មី ទំរាំនឹងស៊ាំនឹងបន្ទប់នៅនិងកន្លែងដាក់អីវ៉ាន់ផ្សេងៗត្រូវប្រើពេលបង្គួរដើម្បីបន្សាំទំលាប់។ យ៉ាងណាមិញ ក្នុងការរៀន បង្រៀន ប្រើពាក្យ ប្រើឃ្លាប្រយោគជាខ្មែរ យើងក៏ត្រូវការផ្សាំឱ្យបានជាទំលាប់ដែរ ។ ពាក្យខេមរយានកម្មខ្លះ ដំបូងប្រើទៅរឹងមាត់ បែបគ្រគ្រើងគ្រញាង បែបមិនពីរោះ ដល់ស៊ាំទៅបែបជាការធម្មតាវិញ

ដូចជាពាក្យ "គំហើញ ចំហេះ ចំហាប" ឥឡូវទៅជាពាក្យធម្មតាអស់ហើយ មិនខុសពីពាក្យបាលីសំស្ក្រឹត "វិទ្ធង្សនា វិច្ឆេទកម្ម បដិវត្តន៍ វិនិយោគ" ដែលទំពាស្ទើរតែមិនបែកនៅដំបូង ដល់ឥឡូវអ្នកណាក៏យល់ ក៏ប្រើគ្រប់ៗគ្នាដែរ ។

ធ្វើអ្វីក៏ដោយ បើខ្វះពាក្យរិះគន់ ខ្វះឧបសគ្គ ការងារនោះមិនសូវចំរើនទេ ។ អនុវត្តន៍ខេមរយានកម្មជួបប្រទះនឹងពាក្យរិះគន់ ឧបសគ្គ សត្រូវ ល្មមដែរ តែគ្រឿងជំទាស់ទាំងនោះបែរជាផ្តល់គុណប្រយោជន៍ចំពោះវឌ្ឍនភាពនៃខេមរយានកម្មទៅវិញ ។ បើតាមរយៈភាសាខ្មែរ សិស្សអាចធ្វើចំណោទធរណីមាត្របាន អាចធ្វើពិសោធន៍គីមីបាន អាចសិក្សាពីមនុស្ស សត្វ រុក្ខជាតិ សិលាជាតិបាន អាចចេះ អាចយល់ អាចចាំ អាចពន្យល់បាន យើងយល់ថាចំណេះវិជ្ជានេះអាចទុកជាបានការហើយ ។

៩.១. តើគណៈកម្មការពិនិត្យ និងប្រមាណលទ្ធផលនៃអនុវត្តន៍ខេមរយានកម្មមានយោបល់យ៉ាងណា ?

តទៅនេះ ជាយោបល់រួមរបស់គណៈកម្មការពិនិត្យ និងប្រមាណលទ្ធផលនៃអនុវត្តន៍ខេមរយានកម្ម ចំពោះសិស្សថ្នាក់ទី ៣ ដែលត្រូវប្រលងមធ្យមសិក្សាប័ត្របឋមភូមិរបបខេមរយានកម្មជាលើកដំបូង ស្រង់ចេញពីរបាយការណ៍ ចុះ

ថ្ងៃ ២០. ០៤. ៧១ :

## សេចក្ដីសង្ខេបរបាយការណ៍គណៈកម្មការពិនិត្យ និងប្រមាណលទ្ធផលនៃអនុវត្តន៍ខេមរយានកម្មនៅមធ្យមសិក្សា

គណៈកម្មការពិនិត្យ និងប្រមាណលទ្ធផលនៃអនុវត្តន៍ខេមរយានកម្ម តែងតាំងឡើងដោយលិខិតបង្គាប់ការលេខ ១៩៨ អទរ-កច ចុះថ្ងៃទី ២៣.០៣.៧១ មានលោក មុំាង ប៉ូរី ជាប្រធាន ក្រោយពីបានដើរពិនិត្យ និងធ្វើអធិការកិច្ចលើសាស្ត្រាចារ្យមួយចំនួននៅក្រុងភ្នំពេញ និងនៅវិទ្យាល័យតាខ្មៅ នាថ្ងៃទី ២៩-០៣-៧១ ដល់ថ្ងៃទី ០១-០៤-៧១ មកបានកត់សំគាល់នូវមូលបញ្ហាដូចតទៅនេះ :

១. ពាក្យពេចន៍ដែលអង្គការខេមរយានកម្មបានបកប្រែឬបង្កើត

គណៈកម្មការបច្ចេកទេសទាំងប្រាំរួមមាន គណៈកម្មការគណិតវិទ្យា ប្រវត្តិ–ភូមិវិទ្យា ធម្មជាតិវិទ្យា រូបវិទ្យា គីមីនិងកីឡា បានទទួលស្គាល់ថា :

ក. ពាក្យពេចន៍មួយភាគធំ ដែលអនុវត្តតាមខេមរយានកម្មមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ មានឯកភាព មានរបៀបរៀបរយសមរម្យ រីឯខ្វះចន្លោះនោះជាការធម្មតាទេ ព្រោះជាកិច្ចការទើបផ្ដើមថ្មី រមែងស្មោកខ្វះមិនខាន ។

ខ សិស្សក្ដីទៅអាចយល់ន័យនៃពាក្យនីមួយៗបានច្បាស់

មិនអាចភ័ន្តច្រឡំ ជារំពេណាយមួយជួយឲ្យចាប់យកមុខវិជ្ជាបានយ៉ាងងាយ ។

គ. សាស្ត្រាចារ្យបានយល់ពាក្យគន្លឹះច្បាស់លាស់ហើយយល់ថា ការបង្កើតពាក្យ ឬបកប្រែ ដែលមានរួចមកហើយនេះ សុទ្ធតែជាការត្រឹមត្រូវ ស្របស្រួលតាមពាក្យបច្ចេកទេសទំនើប ហើយគ្មានអ្វីជាទំនាស់ក្នុងការបង្រៀនឡើយ ។ មកដល់ថ្ងៃនេះ គេប្រព្រឹត្តការងារគេដោយឥតរអាក់រអួលសោះ ។

២. វិធីសាស្ត្របង្រៀនដោយយកភាសាខ្មែរជាយាន

សាស្ត្រាចារ្យទូទៅ យល់ច្បាស់ថា ការបង្រៀនមុខវិជ្ជាជាភាសាខ្មែរ ពុំបានទំនាស់នឹងគោលការណ៍គរុកោសល្យឡើយ ព្រោះ

ក. សិស្សចាប់ស្តាប់បាន ចាប់យល់ ហើយចេះច្បាស់ ពុំស្ទើរស្ទើង បានសេចក្តីថា យល់ហើយ ធ្វើកើតពុំស្ទាក់ស្ទើរ ។

ខ. សិស្សពុំរៀនដោយទន្ទេញមេរៀននីមួយៗឲ្យចាំមាត់តាមតែសាស្ត្រាចារ្យដាក់ឲ្យទេ គឺអាចតែងឃ្លា ប្រយោគបានដោយខ្លួនឯង ពុំចាំបាច់សូត្រតាមសាស្ត្រាចារ្យឡើយ ។

គ. ថ្នាក់នីមួយៗមានសកម្មភាពរស់រវើក ព្រោះសិស្សហ៊ានសាកសួរសាស្ត្រាចារ្យ សួមយោបល់ផ្សេងៗ ចំពោះ

មុខវិជ្ជាណាដែលខ្លួនយល់ថាពុំទាន់ចេះជ្រៅជ្រះ ។

ឃ. សិស្សយល់ច្បាស់នូវសារៈនៃវិជ្ជានីមួយៗ ។

៣. សារៈនៃវិជ្ជា និង កំរិតវិជ្ជាសិស្ស

ក. សារៈនៃវិជ្ជា : តាមយោបល់សាស្ត្រាចារ្យទូទៅ សិស្សអាចក្រេបជញ្ជក់នូវសារៈនៃវិជ្ជាបានយ៉ាងល្អប្រសើរណាស់ ព្រោះសិស្សម្នាក់ៗយល់នូវអត្ថរូប អត្ថន័យនិងអត្ថរស នៃវិជ្ជានោះយ៉ាងជ្រៅជ្រះ ហើយសន្ទុះទឹកចិត្តក៏មានសកម្មភាពខ្លាំងក្លាណាស់ដែរ ។

ខ. កំរិតវិជ្ជាសិស្ស : ប្រសិនបើប្រៀបធៀបកំរិតវិជ្ជាសម័យខេមរយានកម្ម និងសម័យប្រើភាសាបរទេសជាយាន គណៈកម្មការបច្ចេកទេស និង សាស្ត្រាចារ្យទូទៅអាចសន្និដ្ឋានថា កំរិតវិជ្ជាសិស្សសម័យខេមរយានកម្ម ពិតជាខ្ពស់ជាងសម័យសិក្សាវិជ្ជាជាភាសាបរទេស ហើយដោយហេតុតែការសិក្សាវិជ្ជាជាភាសាជាតិ នាំឲ្យសិស្សយល់ឆាប់រហ័ស និងជ្រៅជ្រះនូវខ្លឹមសារនៃវិជ្ជានីមួយៗថែមទៀត ប៉ុន្តែ ក្នុងបច្ចុប្បន្នកាលនេះ គណៈកម្មការមិនអាចធ្វើអត្ថាធិប្បាយឡើយក្នុងវិស័យ ន័យសកលរបស់ពាក្យពេចន៍ ដែលមានបកហើយ ។

អាស្រ័យហេតុនេះ គណៈកម្មការពិនិត្យ និងប្រមាណ

លទ្ធផលនៃអនុវត្តន៍ខេមរយានកម្មយល់ថា ការបន្តខេមរយានកម្មនៅទុតិយភូមិនៃមហាសិក្សាជាការចាំបាច់ណាស់ ដោយយល់ឃើញថា ខេមរយានកម្មសិក្សាពិតជាឆ្លើយតបនឹងសេចក្តីត្រូវការពិតប្រាកដនិងប្រយោជន៍ប្រជាជាតិខ្មែរផង ហើយនិងជួយលើកស្ទួយគំរិតវិជ្ជាសិស្សឱ្យកាន់តែប្រសើរថែមទៀតផង ។

ចំពោះបញ្ហាបាយបង្ហំជុំវិញ ខេមរយានកម្មទៅថ្នាក់លើទៀតនោះ គណៈកម្មការយល់ស្របតាមសេចក្តីសង្កេត និងសំណើទាំងអស់នៃអស់លោកសាស្ត្រាចារ្យនាពេលប្រជុំ ថ្ងៃទី ០២ មេសា ១៩៧១ ក្នុងន័យសំខាន់ទាំងបីគឺ

១. ការលើកទឹកចិត្តគណៈកម្មាធិការជាតិដោយឱ្យមានថេរភាពគ្រប់គ្រាន់ក្រោមការគ្រប់គ្រងនៃច្បាប់បញ្ញត្តិត្រឹមត្រូវ ដើម្បីបំបាត់ភាពតែលតោលដូចជាគ្រាមុនមក ។

២. ការរៀបចំឱ្យបានប្រជុំសាស្ត្រាចារ្យតាមមុខវិជ្ជា ដើម្បីរិះរករូបបន្តថ្មីៗទៀតក្នុងការបន្តខេមរយានកម្ម ។

៣. ការផ្តល់ជំនួយសម្ភារៈ ហិរញ្ញវត្ថុនិងបុគ្គលិកប្រយោជន៍ឱ្យគណៈកម្មាធិការជាតិប្រតិបត្តិការទៅទាន់ពេលវេលា ពុំយឺតយូរ ឬខកខានក្នុងការនិពន្ធសៀវភៅ ឬចងក្រងមេរៀនផ្ញើទៅសាស្ត្រាចារ្យក្នុងក្រុង និងខេត្តក្រៅ ។

៩.២. តើសាស្ត្រាចារ្យបង្រៀននៅមធ្យមសិក្សាមានយោបល់យ៉ាងដូចម្ដេច ចំពោះអនុវត្តន៍ខេមរយានកម្ម ?

យោបល់សាស្ត្រាចារ្យស្រង់ពីអង្គប្រជុំថ្ងៃ ទី ០២-០៤-៧១ (ស្រង់ពីរបាយការណ៍ចុះថ្ងៃទី ២០-០៤-៧១)

សាស្ត្រាចារ្យប្រចាំគ្រប់មុខវិជ្ជា ទាំងអស់បានអញ្ជើញចូលរួមប្រជុំចំនួន ១៥០ រូបតាមសេចក្ដីអញ្ជើញពីគណៈកម្មាធិការក្នុងគោលដៅ គ្រាន់តែប្រមូលយកយោបល់ខ្លះៗទៀតដើម្បីស្រង់ពតិមានឱ្យបានច្រើនសំរាប់ការវិនិច្ឆ័យប៉ុណ្ណោះ ។

១ ពាក្យពេចន៍

ការប្រើពាក្យគន្លឹះទូទៅ មានរបៀបរៀបរយច្រើនហើយដែរ ប៉ុន្តែគប្បី :

ក. ពន្យល់ឱ្យបានច្បាស់សិនជាភាសាខ្មែរ ចំពោះពាក្យបាលីខ្លះ ដែលសិស្សពុំទាន់ដែលប្រើនៅឡើយ ។

ខ. ឱ្យពាក្យថ្មីនីមួយៗប្រកបដោយឯកភាព ព្រោះគេបានសង្កេតឃើញថា ហាក់ដូចជាមានការប្រែប្រួលច្រើនពេក ម្យ៉ាងទៀតពាក្យខ្លះដែលគណៈកម្មាធិការជាតិបញ្ចេញមិនទាន់ សាស្ត្រាចារ្យលែបកខ្លួនឯង ម្ល៉ោះហើយជួនកាលខុសឬមិនស្របគ្នាទាល់តែសោះ ។

គ. បញ្ជាក់អំពីន័យ "វិទ្យាសាស្ត្រសកល" ដើម្បីកុំឱ្យ

ឃ្លាតឆ្ងាយពីលក្ខណៈអន្តរជាតិពេក ។

២ ការយល់យល់របស់សិស្ស

ការសិក្សាដោយយកភាសាជាតិជាយាន បានផ្តល់អត្ថប្រយោជន៍ច្រើនជាអនេក ព្រោះគេអាចក្រេបជញ្ជក់យកវិជ្ជាឆាប់រហ័ស ចំណែកអស់លោកសាស្ត្រាចារ្យក៏ងាយបង្រៀនដែរ ។ ក្នុងបច្ចុប្បន្នកាល ដែលខេមរយានកម្មកំពុងតែប្រព្រឹត្តទៅរហូតដល់ថ្នាក់ទី៣ទៅហើយ គេបានសង្កេតឃើញលទ្ធផលប្រសើរៗ ព្រមទាំងសន្ទុះអបអរទៀតសោតក៏មានទៅមុខពិតប្រាកដ ។

៣– ការយល់យល់របស់សាស្ត្រាចារ្យ

អង្គប្រជុំបានឲ្យយោបល់ថា រឿងដែលឲ្យមានឧបសគ្គខ្លះៗនោះជាហេតុបច្ច័យតូចតាចទេ ដោយសុទ្ធតែជាបញ្ហាអាចដោះរួច ដោយមធ្យោបាយដូចតទៅ :

សុំឲ្យមានសហការពីអស់លោកសាស្ត្រាចារ្យថ្នាក់ខ្ពស់ៗតាមឯកទេសភាពនីមួយៗ

បង្គាប់ឲ្យនិស្សិតសាស្ត្រាចារ្យតែងនិក្ខេបបទ
de sortie) ជាសៀវភៅសិក្សាដោយបញ្ចេញជាវិធីសាស្ត្រស្រាវជ្រាវដោយខ្លួនឯង

គប្បីធ្វើយ៉ាងដូចម្តេចឲ្យសៀវភៅចេញរហ័ស ហើយទាន់ពេលវេលា ដូច្នេះបើទោះជាសៀវភៅមិនទាន់ គួរគប្បីផ្តិតរ៉ូនេអូ ហើយចងជាកំរងផ្ញើទៅសាស្ត្រាចារ្យ

សុំទីស្តីការរដ្ឋមន្ត្រីបំពេញសេចក្តីត្រូវការខាងបុគ្គលិកទៅគណៈកម្មាធិការជាតិ ឲ្យបានចំនួនគ្រប់គ្រាន់អាចឲ្យគណៈកម្មាធិការជាតិនេះមានជំហរនឹង ប្រកបដោយការឧបត្ថម្ភពេញលេញពីក្រសួងសិក្សាធិការ ទោះក្នុងផ្លូវការក្តីឬក្នុងវិស័យសម្ភារៈសព្វបែបយ៉ាងក្តី ។

សុំទីស្តីការរដ្ឋមន្ត្រីគ្រោងបើកនៅវិស្សមកាលខាងមុខនូវសិក្ខាកម្ម ឬការវគ្គ តាមមុខវិជ្ជាដើម្បីរិះរកមាគ៌ាដើរឲ្យចំៗ ។

៩ ៣ តើគណៈមេប្រយោគប្រលងមធ្យមសិក្សាប័ត្របឋមភូមិយល់ដូចម្តេច ?

តទៅនេះជាយោបល់រួម ស្រង់ចេញពីរបាយការណ៍រួមនៃគណៈមេប្រយោគប្រលងមធ្យមសិក្សាប័ត្របឋមភូមិឆ្នាំ ១៩៧០-៧១ របបខេមរយានកម្មជាលើកដំបូង ។

យោបល់រួម. “ អនុវត្តន៍ខេមរយានកម្មនៅមធ្យមសិក្សាបានប្រកបដោយជោគជ័យ ។ លទ្ធផលបានល្អជាងឆ្នាំមុនៗ

ទោះខ្វះឯកភាពក្នុងការប្រើពាក្យក៏ដោយ ។ សិស្សមិនបាច់ទន្ទេញមេរៀនចាំមាត់អាចយល់សំណួរបានស្រួលបានច្បាស់ អាចបញ្ចេញគំនិតរបស់ខ្លួនបានដោយងាយ" ។

៩៤ តើការប្រលងមធ្យមសិក្សាប័ត្រ បឋមភូមិ របបខេមរយានកម្ម ជាលើកដំបូងផ្តល់លទ្ធផលបែបណា ?

## លទ្ធផលប្រលងមធ្យមសិក្សាប័ត្របឋមភូមិ

(ស្ថិតិនាយកដ្ឋានមធ្យមសិក្សា និងលិខិតនាយកមធ្យមសិក្សា លេខ ៣៧៨៤ នមសកប្រ-ជ១ ចុះថ្ងៃ២៦-១០-៧១)

| ឆ្នាំសិក្សា | មកប្រលង | ជាប់ | ភាគរយ | សង្កេត |
| --- | --- | --- | --- | --- |
| ១៩៦០-៦១ | ៦ ២៧៦ | ១ ៤៧៤ | ២៣,៤៨% | មុនរបប ខេមរយានកម្ម |
| ១៩៦១-៦២ | ៩ ៣៣៣ | ២ ១៦០ | ២៣,១៤% | |
| ១៩៦២-៦៣ | ១២ ៣៤៨ | ៣ ៤៥៨ | ២៨,០០% | .. |
| ១៩៦៣-៦៤ | ១៥ ៣២៥ | ៣ ៧២៧ | ២៤,៣១% | .. |
| ១៩៦៤-៦៥ | ១៦ ៣២០ | ៥ ៦៤៣ | ៣៤,៥៧% | .. |
| ១៩៦៥-៦៦ | ១៨ ២៥១ | ៧ ៧១៦ | ៤២,២៧% | .. |
| ១៩៦៦-៦៧ | ១៨ ៨១០ | ៥ ៨៩៣ | ៣១,៣២% | .. |
| ១៩៦៧-៦៨ | ២២ ១៥០ | ៦ ៥៦១ | ២៩,៦២% | .. |
| ១៩៦៨-៦៩ | ២៣ ០០៤ | ៨ ៧៩៤ | ៣៨,២២% | .. |
| ១៩៦៩-៧០ | ២១ ៤៦៨ | ១៨ ៧០០ | ៨៧,១០% | .. |
| ១៩៧០-៧១ | ១៣ ៤៣៨ | ៧ ៤០៧ | ៥៥,១១% | របបខេមរ យានកម្ម |
| | ៤៦៣៦ | ១ ១៦៥ | ២៥,១២% | របបបរទេស យានកម្មសល់ ពីមុន |

សង្កេតទី១.- នៅឆ្នាំ ១៩៦៩-៧០ ភាគរយក្នុងរបបបរទេសយានកម្មមានកំរិតខ្ពស់ដល់ទៅ ៨៧,១០% បណ្ដាលមកពីសេចក្ដីអនុគ្រោះដ៏ពេញបន្ទុករបស់ក្រសួងអប់រំជាតិ ។

សង្កេតទី ២. នៅឆ្នាំ ១៩៧០-៧១ភាគរយក្នុងរបបខេមរយានកម្ម មានកំរិតខ្ពស់ដល់ទៅ ៥៥,១១% ដាច់ពីភាគរយនៃឆ្នាំសិក្សាទាំងអស់ ដេញពីឆ្នាំសិក្សា ១៩៦៨ ៦៩ ឋយក្រោយដោយសតបានទទួលសេចក្ដីអនុគ្រោះអ្វីផង ។

សង្កេតទី ៣. នៅឆ្នាំ ១៩៧០-៧១ ដដែល ក្រសួងនៅអនុញ្ញាតបេក្ខជនរបបខេមយានកម្មឲ្យបកប្រលងទៀត ។

## ១០. ខេមរយានកម្ម និង ភាសាបរទេស

ចាប់ផ្ដើមធ្វើខេមរយានកម្មភ្លាម អង្គការខេមរយានកម្មផ្សាយមិនឈប់ឈរថា ខេមរយានកម្មពុំមែនជាសត្រូវនឹងភាសាបរទេសឡើយ ។ ពុំមែនគ្រាន់តែពុំមែនជាសត្រូវ ខេមរយានកម្ម និងភាសាបរទេសត្រូវដើរទន្ទឹមគ្នា ត្រូវជួយគ្នាដឹកនាំសិស្សខ្មែរទៅកាន់សេចក្ដីចំរើន ។ ខេមរយានកម្មជាច្រកដោះស្រាយមួយជួយសិស្សឲ្យឆាប់យល់ ឆាប់ចេះ ឆាប់ចាំមេរៀនទានាជាភាសាខ្មែរប្រយោជន៍នឹងឲ្យចំណេញពេល

យកទៅទុករៀនភាសាបរទេស ។ ចេះភាសាបរទេសកាន់តែបានច្រើនកាន់តែល្អ ហើយត្រូវតែចេះជាចាំបាច់នូវភាសាបរទេសណាដែលជាសត្រូវរបស់ជាតិ រដ្ឋគប្បីពង្រីកការសិក្សាភាសាបរទេសអន្តរជាតិ និងភាសាបរទេសជិតខាងឲ្យបានផ្ចិនបែនទែន ចំពោះសិស្សនិងនិស្សិតខ្មែរដោយបញ្ជាក់ឲ្យច្បាស់ថា សិក្សាភាសាបរទេសក្នុងឋានៈជាជីវភាសា ពុំមែនជាភាសាយាន ។

អង្គការខេមរយានកម្មតែងផ្សាយរឿងនេះជំរាបមហាជន ដើម្បីកុំឲ្យយល់ច្រឡំថា ធ្វើខេមរយានកម្មលុបភាសាបរទេស ( បារាំង អង់គ្លេស ) ។

បើក្រឡេកមើលពេលម៉ោងក្នុងកម្មវិធីសិក្សាវិញ ចំនួនម៉ោងសិក្សាភាសាបរទេសនៅតែច្រើនដដែលគឺ

—នៅថ្នាក់ទី ៦ : ៩ ម៉ោងក្នុងមួយអាទិត្យ
— — ៥ : ៩ —
— — ៤ : ៧ —
— — ៣ : ៧ —
— — ២ : ៦ — ( ភាសាបរទេសទី១ )
— — — : ៣ — ( ភាសាបរទេសទី២ )
— — ១ : ៦ — ( ភាសាបរទេសទី១ )

— នៅថ្នាក់ទី១ : ២ — ( ភាសាបរទេសទី២ )

— នៅថ្នាក់បញ្ចប់ :

(ថ្នាក់ទស្សនវិជ្ជា) : ៧ — ( ភាសាបរទេសទី ១ )

— : ៣ — ( ភាសាបរទេសទី២ )

(ថ្នាក់គណិតវិទ្យា) : ៥ — ( ភាសាបរទេសទី ១ )

— : ២ — ( ភាសាបរទេសទី២ )

(ថ្នាក់វិទ្យាសាស្ត្រ): ៥ — ( ភាសាបរទេសទី ១ )

— : ២ — ( ភាសាបរទេសទី២ )

## ១១. ខេមរយានកម្ម និង អង្គការរដ្ឋនានា

នៅប្រទេសថៃក្តី ប្រទេសម៉ាឡាយូក្តី រដ្ឋាភិបាលតែម្តង ជាអ្នកអនុវត្តដោយខ្លួនឯង ជាអ្នកបញ្ជាក្រសួងនានាឲ្យអនុវត្ត ការប្រើភាសាជាតិជាទូទៅ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលនិង បញ្ចូនគ្គចូលប្រឡូកក្នុងវិស័យអភិវឌ្ឍន៍វប្បធម៌ជាតិ ជាពិសេស ក្នុងផ្នែកភាសា និងអក្សរសាស្ត្រជាតិដោយណែនាំឲ្យស្រឡាញ់ចូលចិត្តចាប់អារម្មណ៍ ហើយនិងដោយផ្តល់បញ្ញាបាយគ្រប់គ្រាន់ ដើម្បីចាត់ការ ។

រីឯខេមរយានកម្មវិញ ដោយពីក្រោមឡើងទៅលើជាហេតុនាំឲ្យមានឧបសគ្គគ្រប់បែបយ៉ាង ។ រហូតមកដល់សព្វ

ថ្ងៃនេះ អង្គការរដ្ឋមួយភាគធំពុំទាន់ជួយតាមផ្លូវចិត្តនូវអនុវត្តន៍ខេមរយានកម្មក្នុងកិច្ចការរដ្ឋបាល ។

ដើម្បីឲ្យខេមរយានកម្មប្រព្រឹត្តទៅបានស្រួល ត្រូវតែរដ្ឋាភិបាលនេះតែម្តងក្តាប់រឿងនេះឲ្យមាំ ហើយមានជំនឿនិងទំនុកចិត្តច្បាស់ពីតំលៃនៃភាសាជាតិ ។

## ១២. ខេមរយានកម្ម និង មតិសាធារណជន

ចាប់តាំងពីមានខេមរយានកម្មមក អង្គការនេះបានផ្សព្វផ្សាយពត៌មានខេមរយានកម្មគ្រប់យ៉ាងដល់សាធារណជនឲ្យបានជ្រួតជ្រាបតាមរយៈវិទ្យុជាតិ ក្នុងនាទីខេមរយានកម្មរាល់ល្ងាចថ្ងៃព្រហស្បតិ៍ ។ បើគិតពីឆ្នាំ ១៩៦៨ មកទល់ថ្ងៃនេះ យ៉ាងហោចណាស់ខេមរយានកម្មបានផ្សាយ ២២០ ដង នេះមិនគិតដល់ការផ្សាយផ្សេងៗ ក្រៅនាទីខេមរយានកម្មផង ។

ក្រៅពីនាទីខេមរយានកម្មតាមវិទ្យុជាតិ ពត៌មានខេមរយានកម្មជាច្រើនត្រូវផ្សាយចេញតាមព្រឹត្តិប័ត្រ ទស្សនាវដ្តីនិងសៀវភៅសិក្សាថែមទៀត ។

រីឯសំបុត្ររបស់ប្រជាពលរដ្ឋដូចជាសិស្ស និស្សិត ទាហាន ព្រះសង្ឃ ។ល។ អង្គការខេមរយានកម្មក៏បានទទួលច្រើន

ណាស់ដែរ ជាសំបុត្រសរសើរក៏មាន រិះគន់ឲ្យកែច្នៃក៏មាន សួរធ្លូលក៏មាន ។ អគ្គលេខាធិការដ្ឋានខេមរយានកម្មបាន ឆ្លើយជាផរាប ដោយមិនភ្លេចសំដែងអំណរគុណចំពោះ ចំណាប់អារម្មណ៍របស់អស់លោកទាំងនោះ មកលើអង្គការ ខេមរយានកម្ម ។

០៤ សីហា ១៩៧២

# ឧបសម្ព័ន្ធ

## ជំហាននៃការប្រើភាសាជាតិ

ក្នុងសម័យប្រជុំកាលពីថ្ងៃអង្គារទី ២១ ធ្នូ ១៩៧១ គណៈរដ្ឋមន្ត្រីបានអនុម័តជាគោលការណ៍ថា យកភាសាជាតិជាភាសាយានក្នុងការប្រលងប្រជែងនានា ។

យើងមានសេចក្ដីរីករាយ ចំពោះគំនិតដ៏ប្រសើរនេះណាស់ ពីព្រោះជាគំនិតជាតិនិយមដ៏ខ្ពស់មួយដែលជួយជំរុញខេមរយានកម្មសិក្សាឱ្យរឹតតែមានដំណើរល្អតទៅមុខទៀត ។

បានជាថាដូច្នេះ ពីព្រោះសិស្សានុសិស្សសម័យខេមរយានកម្មមានសេចក្ដីព្រួយបារម្ភណាស់ និងច្រើនតែអស់សង្ឃឹមចំពោះការប្រលងប្រជែង ដែលមិនប្រើភាសាខ្មែរជាភាសាយាននេះម្យ៉ាង ម្យ៉ាងទៀតពិតមែនតែមាត្រានៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ បញ្ញត្តឱ្យប្រើភាសាជាតិជាផ្លូវការ ក៏អនុវត្តន៍ភាសាខ្មែរនេះនៅមិនទាន់បានល្អមួយរយភាគរយដែរ ។ ឥឡូវ បើក្នុងការប្រលងប្រជែងនានា ភាសាខ្មែរមាននាទីសំ

ខាន់ហើយ យើងសង្ឃឹមថា ខេមរយានកម្មអាចនឹងជ្រួតជ្រាបទៅក្នុងសកម្មភាពយើងគ្រប់បែបយ៉ាងទាំងអស់ ហើយនិងចាក់ឫសយ៉ាងមាំនៅក្នុងសកម្មភាពនោះៗ ។ ដូច្នេះទៅអនាគត ភាសាខ្មែរនឹងរឹតតែមានតំលៃជាពិតប្រាកដ ។

យើងសូមសរសើរនិងសង្ឃឹមជាថ្មីម្តងទៀត ចំពោះគណៈរដ្ឋមន្ត្រីដែលមានមនសិការជាតិដ៏ខ្ពង់ខ្ពស់ ក្នុងរៀងសំរេចឲ្យប្រើភាសាជាតិជាភាសាយានក្នុងការប្រលងប្រជែងនានា និងសូមឲ្យអនុម័តិជាគោលការណ៍នេះក្លាយទៅជាសេចក្តីសំរេចប្រកបដោយប្រសិទ្ធិភាពពិតប្រាកដក្នុងកិច្ចអនុវត្តន៍ចាប់តាំងពីពេលនេះតរៀងទៅ ។

ទីស្តីការរដ្ឋមន្ត្រី                    ភ្នំពេញ ថ្ងៃទី ៦ មិថុនា ឆ្នាំ ១៩៧២

ក្រសួងអប់រំជាតិ និង វប្បធម៌

លេខ : ១៥៧៥ អ.ល.ខ.

រដ្ឋមន្ត្រីក្រសួងអប់រំជាតិនិងវប្បធម៌

ជំរាបមក :

– លោកអគ្គនាយកនានានៃក្រសួងអប់រំជាតិនិងវប្បធម៌

– លោកនាយកសកលវិទ្យាល័យទាំងអស់នៃក្រសួងអប់រំជាតិ

លោកនាយកខុទ្ទកាល័យនៃទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំជាតិ

លោកនាយកការិយាល័យនៃទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំជាតិ

លោកអធិការអមទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំជាតិ

លោកនាយកនានា នៅក្រោមឱវាទក្រសួងអប់រំជាតិ

លោកនាយកការិយាល័យ ទាំងអស់ នៃទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំជាតិ

**កម្មវត្ថុ** : ការប្រើភាសាខ្មែរ

**យោង** : លិខិតក្រសួងលេខ ២៥២៦ អចរ–កច ចុះថ្ងៃទី ២២-៧-៧១

យោងតាមលិខិតខាងលើនេះ ខ្ញុំសុំរំលឹកលោក-អ្នកទាំងអស់ដែលនៅក្រោមឱវាទក្រសួងអប់រំជាតិនិងវប្បធម៌ ឱ្យប្រើភាសាខ្មែរជាដាច់ខាត លើកលែងតែការទាក់ទងជាមួយនឹងអគ្គការបរទេស ។

ជ. រដ្ឋមន្ត្រីក្រសួងអប់រំជាតិនិងវប្បធម៌

អនុរដ្ឋលេខាធិការ

ហត្ថលេខា : ប៉ាន់ ឡូរ

សាធារណរដ្ឋខ្មែរ
សភាជាតិ

# សេចក្ដីសំរេចនៃសភាជាតិ
# នាថ្ងៃទី ២០ តុលា ១៩៧២

— ដោយយល់ឃើញថា ការមិនព្រមប្រើភាសាខ្មែរជាផ្លូវការ ឬការប្រើភាសានេះដោយខ្ជីខ្ជាជាការរំលោភលើរដ្ឋធម្មនុញ្ញសាធារណរដ្ឋ នៃថ្ងៃ ១០-៥-៧២ ត្រង់មាត្រា ២ វគ្គទី ៤

— ដោយយល់ឃើញថា មានការរិះគន់ពីគ្រប់មជ្ឈដ្ឋានចំពោះអង្គការរដ្ឋនានា ដែលសរសេរឆ្លើយឆ្លងគ្នាជាភាសាបរទេស

— ដោយយល់ឃើញថា ការប្រើភាសាបរទេសក្នុងលិខិតឆ្លើយឆ្លងនេះធ្វើឲ្យការអនុវត្តន៍ពុំអាចប្រព្រឹត្តទៅបានរហ័សទាន់ចិត្ត ហើយជាការបង្ខំខាងផ្លូវចិត្តមួយឲ្យខ្មែរបង្អាប់ភាសាខ្មែរ

— ដោយយល់ឃើញថា ការប្រើភាសាជាតិជាផ្លូវការធ្វើឲ្យងាយស្រួលក្នុងការទាក់ទងក្នុងក្របខ័ណ្ឌចលនាប្រជារាស្ត្រ ធ្វើឲ្យឯកភាពខាងការសរសេរនិងនិយាយខ្មែរ បានកាន់តែប្រសើរឡើង ធ្វើឲ្យវប្បធម៌អក្សរសាស្ត្រខ្មែរកាន់តែរីកដុះដាលក្នុងផ្ទៃប្រទេស និងក្រៅប្រទេស ធ្វើឲ្យអ្នកចេះភាសាជាតិអាចរកការធ្វើបានដោយងាយ

— ដោយយល់ឃើញថា ក្នុងចំបាំងឈ្លានពានលេបទឹកដី ភាសាជាតិជាគោលជំហរវប្បធម៌មួយធំជាងគេ ទប់កុំឲ្យប្រជាជាតិនីមួយៗរលាយសាបសូន្យទៅបានដោយងាយ

សភាជាតិ នាសម័យប្រជុំពេញអង្គលើកទី ១៣ នៅថ្ងៃ ២០ តុលា គ.ស.១៩៧២ បានសំរេចជាឯកច្ឆ័ន្ទគាំទ្ររដ្ឋាភិបាល :

១. ចាត់វិធានការជាចាំបាច់និងដោយរួសរាន់ ដើម្បីអនុវត្តរដ្ឋធម្មនុញ្ញក្នុងការប្រើភាសាខ្មែរជាផ្លូវការទាំងអស់ ខាងអង្គការរដ្ឋ ក៏ដូចខាងជំនួញ និងសកម្មភាពទាំងអស់ក្នុងស្រុក

២. ធ្វើគំរោងការអំពីការអនុវត្តន៍នេះផ្ញើមកសភាជាតិឲ្យបានមុនថ្ងៃ ៣១ មករា ១៩៧៣ ជាដាច់ខាត និងដាក់ទណ្ឌកម្មដល់នរណាដែលមិនគោរពច្បាប់នេះផង ។

ភ្នំពេញ ថ្ងៃទី ២០ ខែតុលា គ.ស.១៩៧២

ប្រធានសភាជាតិ

ហត្ថលេខា : តាន់ គឹមហួន

សាធារណរដ្ឋខ្មែរ          ភ្នំពេញ ថ្ងៃទី ៦ វិច្ឆិកា គ.ស. ១៩៧២

ទីស្ដីការរដ្ឋមន្ត្រីទី ១          សារាចរ

លេខ ១.៣៨ អ.ល. រម ១ ក.ទ.សា.          រដ្ឋមន្ត្រីទីមួយ

សូមជំរាបមកសមាជិកនៃរដ្ឋាភិបាលទាំងអស់ ភ្នំពេញ ។

កម្មវត្ថុ : ការប្រើភាសាខ្មែរជាផ្លូវការ

ខ្ញុំសូមជំរាបថា សភាជាតិបានសំរេចចិត្តកាលពីថ្ងៃទី ២០ ខែតុលា ឆ្នាំ ១៩៧២ ឲ្យប្រើភាសាខ្មែរជាផ្លូវការទាំងអស់ ទាំងខាងអគ្គការរដ្ឋ ក៏ដូចខាងជំនួញ និងសកម្មភាពទាំងអស់ក្នុងស្រុក ដើម្បីជាការអនុវត្តន៍រដ្ឋធម្មនុញ្ញ ត្រង់មាត្រា ២ វគ្គទី ៤ ដែលមានចែងយ៉ាងច្បាស់លាស់ក្នុងរឿងនេះ ។

ដូច្នេះ ខ្ញុំសូមអស់លោកចាត់វិធានការឲ្យប្រើភាសាខ្មែរជាផ្លូវការតាមសេចក្ដីសំរេចចិត្តខាងលើ ចាប់តាំងពីពេលនេះតទៅ រួចសុំធ្វើគំរោងការនៃការអនុវត្តន៍នេះផង ។

ជូនជាប់មកនេះ សេចក្ដីសំរេចនៃសភាជាតិនាថ្ងៃទី ២០ ខែតុលា ឆ្នាំ ១៩៧២ ។

ហត្ថលេខា : ហង្ស ធុន ហាក់